សមាគមអាដហុក
ADHOC

# ស្ថានភាពវិវាទដីធ្លី ២០២១








## ការបន្តចោទប្រកាន់-ការចាប់ឃុំខ្លួនពលរដ្ឋ ក្នុងរឿងវិវាទដីធ្លី

**ភ្នំពេញ ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២២**

**ផ្សព្វផ្សាយដោយ៖** សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
**កាលបរិច្ឆេទ៖** ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២២
Address: #3, St 158 Ouknha Trorung Kang, Boeng Raing, Saun Penh, Phnom Penh
Tel: (+855-23) 218 553/210 518/990 544
P.O Box: 1024 – P.O Box 20 at CCC
E-mail: info@adhoccambodia.org
Website: www.adhoccambodia.org
Facebook: www.facebook.com/adhoccam
Twitter: www.twitter.com/adhoccam

# មាតិកា


**ទំព័រ**

**I. សេចក្ដីផ្ដើម** ........................................................................................ ៤

**II. ប្រវត្តិកម្មសិទ្ធិលើដីធ្លី** ........................................................................ ៩

**III. មូលហេតុការចាប់ខ្លួនចោទប្រកាន់វិវាទដីធ្លី**

១. បំបាក់ស្មារតី ........................................................................................ ១០

២. ឥទ្ធិពលអ្នកមានអំណាច-មានទ្រព្យ និងខ្វះការពិគ្រោះយោបល់ជាសាធារណៈគម្រោងអភិវឌ្ឍន៍ ........................................................ ១៧

៣. ការអនុវត្តច្បាប់មិនពេញលេញ ........................................................ ២០

**IV. ក្របខណ្ឌគតិយុត្តិ**

ច្បាប់ជាតិ ........................................................................................ ២៣

ច្បាប់អន្តរជាតិ និងយន្តការសិទ្ធិមនុស្ស ................................................ ២៤

**V. យន្តការដោះស្រាយវិវាទ** ........................................................ ២៦

**VI. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍** ................................................ ២៧

**VII. ឧបសម្ព័ន្ធ** ( ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២០-២០២១ )................................ ២៩

I. **សេចក្តីផ្តើម**:

នៅប្រទេសកម្ពុជា ជម្លោះដីធ្លីតែងតែកើតមានឡើងឥតឈប់ឈរ ប្រៀបដូចជាជំងឺរ៉ាំរ៉ៃនៅក្នុងសង្គមដែលពិបាកព្យាបាល "*រឿងចាស់មិនទាន់ដោះស្រាយ - រឿងថ្មីកើតឡើង ហើយកាន់តែមានចរិកលក្ខណៈធ្ងន់ធ្ងរ រំលោភសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិមនុស្សជាសកល* " ជាពិសេសបំបាក់ស្មារតីប្រជាពលរដ្ឋសាមញ្ញក្នុងរឿងជម្លោះដីធ្លី តាមរយៈការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ និងប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួន ប្រជាពលរដ្ឋក្នុងរឿងជម្លោះដីធ្លី លើសពីនេះទៀតឥទ្ធិពលអ្នកមានអំណាច-អ្នកមានទ្រព្យធន(ឧកញ៉ា) បាននឹងកំពុងឆ្លៀតឱកាស ប្រើប្រាស់ស្ថានភាពដ៏ គ្រោះថ្នាក់អំឡុងពេលរីករាលដាលជំងឺកូវីត១៩ ដើម្បីជាប្រយោជន៍ក្នុងរឿងជម្លោះដីធ្លីឆ្នាំ២០២១នេះ ។ ដូចជា ករណីអាជ្ញាធរចាប់បញ្ជូនប្រជាពលរដ្ឋរស់នៅភូមិកំពង់តាឡុង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចំនួន០៤នាក់ ធ្វើចត្តាឡីស័ក១៤ថ្ងៃ នៅវិទ្យាល័យកំពង់កន្ទួត ទាំងមិនបានធ្វើសំណាកជាមុនដោយសំអាងថា អ្នកទាំងនោះមានជាប់ពាក់ព័ន្ធនឹងអ្នកជម្ងឺកូវិត១៩ ហើយរឿងនេះបានកើតឡើង បន្ទាប់ពីពួកគេត្រឡប់មកពីដាក់ញាតិ នៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។ ករណីអាជ្ញាធរផាកពិន័យចំនួន២លានរៀល ដោយគ្រាន់តែប្រជាពលរដ្ឋឈរថតរូបជុំគ្នាកណ្តាលវាលស្រែ តវ៉ារឿងជម្លោះដីស្រែបាត់បង់មិនបានពាក់ម៉ាស់ នៅភូមិចេក ឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

**របាយការណ៍ឆ្នាំ២០២១៖** សមាគមអាដហុកទទួលបានការស្នើសុំអន្តរាគមន៍ពីប្រជាសហគមន៍រងគ្រោះករណីវិវាទដីធ្លី សរុបចំនួន ១៦៩ករណីមានទំហំដីវិវាទសរុបចំនួន៥២,៦០១.៨៧ ហិកតានិងប៉ះពាល់ជនរងគ្រោះចំនួន ១៧,០៣៣ គ្រួសារ (ជនជាតិដើមភាគតិចចំនួន១,៣៤៧ គ្រួសារ) ស្មើ និងចំនួនមនុស្សសរុប ៦១,៤៦៩នាក់ ។ ប្រភេទវិវាទដីធ្លីដែលឈរលំដាប់ថ្នាក់ខ្ពស់ជាងគេបំផុតក្នុងឆ្នាំ២០២១ គឺករណីរំលោភដោយបុគ្គលមានអំណាចចំនួន ៦៦ករណីវិវាទ និង ជាបន្ទាប់ ករណីរំលោភដោយអ្នកមានទ្រព្យចំនួន២៧ករណី។




របាយការណ៍បានរកឃើញថា៖ ២៣.៦៦% នៃវិវាទ១៦៩ករណី គឺជាករណីវិវាទដីធ្លីមានការចាប់ខ្លួនចោទប្រកាន់ ឃុំខ្លួន ប្រជាពលរដ្ឋជាគូភាគីវិវាទដែលក្នុងនោះមាន ៣៥ករណី ជនរងគ្រោះ ១៥៧នាក់កំពុងជាប់បណ្តឹងអាជ្ញា (ដាក់ក្រោមការត្រួតពិនិត្យតុលាការ) និង ៦ករណីមានជនរងគ្រោះ ១៧នាក់កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្នរហូតមានជនរងគ្រោះម្នាក់ធ្លាក់ខ្លួនមានជម្ងឺធ្ងន់ធ្ងរនិងស្លាប់ក្រោយពេលបញ្ជូនពីពន្ធនាគាដល់មន្ទីរពេទ្យ ។ ជាមួយគ្នានេះផងដែរ នៅមានករណីមួយចំនួនទៀត ប្រជាសហគមន៍រងគ្រោះដីធ្លីជាច្រើនក៏ជាប់បណ្តឹងអាជ្ញា និងដាក់ក្រោមការត្រួតពិនិត្យតុលាការដូចជា៖ នៅខេត្តត្បូងឃ្មុំ មានប្រជាសហគមន៍រងគ្រោះដីធ្លីរហូតដល់៤៤នាក់ ត្រូវបានជាប់បណ្តឹងអាជ្ញា និងដាក់ក្រោមការត្រួតពិនិត្យតុលាការ ខេត្តឧត្តមានជ័យ២៨នាក់ ខេត្តកណ្តាល ២១នាក់ ខេត្តក្រចេះ១៨

នាក់ និងខេត្តកំពង់ស្ពឺ ១៥នាក់ ។ ***ឧបសម្ពន្ធ(១)៖ ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២១ (តាមខេត្តនិមួយៗ ) ទំព័រទ២៨ និងឧបសម្ពន្ធ(២)៖ ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២១(តាមអាណិត្ត) ទីព័រទី៣០***

**របាយការណ៍ឆ្នាំ២០២០ ៖** សមាគមអាដហុក ទទួលបានករណីវិវាទដីធ្លីសរុបចំនួន១៨២ករណី ដែលមានទំហំដីវិវាទសរុបចំនួន៥៧,០៨៦.៨៥ ហិកតា ប៉ះពាល់ជនរងគ្រោះសរុបចំនួន ២៣,៣៩១ គ្រួសារ(ជនជាតិដើមភាគតិចចំនួន ៥,២៨៤គ្រួសារ) ស្មើនិងមនុស្សសរុប៧៧,៣៦១នាក់ ។ ប្រភេទវិវាទដីធ្លីដែលឈរលំដាប់ថ្នាក់លេខមួយ គឺករណីរំលោភដោយបុគ្គលមានអំណាចចំនួន៩៣ករណីវិវាទ និងករណីរំលោភដោយអ្នកមានទ្រព្យស្ថិតក្នុងលំដាប់ថ្នាក់លេខ២មានចំនួន២០ករណី។ របាយការណ៍បានរកឃើញ៖២៥.២៧% នៃ១៨២




ករណី គឺជាករណីវិវាទដីធ្លីមានការចាប់ខ្លួន ចោទប្រកាន់ ឃុំខ្លួនប្រជាពលរដ្ឋគូភាគីវិវាទ ដែលក្នុងនោះមាន ៤៣ករណី ជនរងគ្រោះ១៦៥នាក់កំពុងជាប់បណ្តឹងអាជ្ញា (ដាក់ក្រោមការត្រួតពិនិត្យតុលាការ) និង ៤ករណី ជនរងគ្រោះ ១៤នាក់កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ***ឧបសម្ពន្ធ(៣)៖ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២០(តាមខេត្តនិមួយៗ)ទីព័រទី៣១និងឧបសម្ពន្ធ(៤)៖ ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២០ (តាមអាណិត្ត) ទីព័រទី៣៣។***

**ខេត្តកណ្តាល** មានអត្រាវិវាទដីធ្លីធំៗកើនឡើងខ្ពស់គួរអោយកត់សំគាល់ ចាប់តាំងពីចុងឆមាសទី១ ដល់ចុងឆ្នាំ២០២១នេះ! ចំណាត់ថ្នាក់ខ្ពស់នោះ គឺវិវាទដីធ្លីមានលក្ខណៈកាន់តែធ្ងន់ធ្ងរហើយករណីវិវាទទាំងនោះសុទ្ធតែប្រើអំពើហឹង្សា វាយបង្ក្រាប បាញ់ប្រហាររបួសធ្ងន់ ចាប់ខ្លួន ចោទប្រកាន់ឃុំខ្លួនប្រជាពលរដ្ឋភាគីទំនាស់រហូតដល់ធ្លាក់ខ្លួនឈឺធ្ងន់នៅក្នុងពន្ធនាគារ ហើយត្រូវបានស្លាប់បន្ទាប់ពីបញ្ជូនដល់មន្ទីរពេទ្យ និងករណីខ្លះប្រជាពលរដ្ឋភ័យខ្លាចរហូតដល់រត់ចោលលំនៅដ្ឋានស្នាត់ភូមិជ្រងំដោយនៅសល់តែឪពុកម្តាយចាស់ជរា និងកូនតូចៗនៅចាំផ្ទះប៉ុណ្ណោះ....ដូចជាករណី៖

① **ស្រុកកណ្តាលស្ទឹង៖** ជាមួយក្រុមហ៊ុនអូស៊ីអាយស៊ី ធ្វើព្រលានយន្តហោះ និងប្រជាពលរដ្ឋជាង ៣០០គ្រួសារ - ជម្លោះដីធ្លីដែលបានអូសបន្លាយពេលជាងបីឆ្នាំកន្លងមក មានកំដៅឡើងវិញបន្ទាប់ពីអាជ្ញាធរ បានចាប់បញ្ជូនប្រជាពលរដ្ឋរស់នៅភូមិកំពង់តាឡុង ឃុំបឹងខ្យាង ចំនួន០៤នាក់ធ្វើចត្តាឡីស័ក១៤ថ្ងៃ នៅវិទ្យាល័យកំពង់កន្ទួតមិនបានធ្វើសំណាកជាមុនដោយសំអាងថាអ្នកទាំងនោះមានជាប់ពាក់ព័ន្ធនឹង អ្នកជម្ងឺកូវិត១៩ ហើយរឿងនេះបានកើតឡើង បន្ទាប់ពីពួកគេត្រឡប់



មកពីដាក់ញាតិនៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១។ ហើយមួយខែ

ក្រោយមកនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំដដែល អាជ្ញាធរបានចាប់ខ្លួនប្រជាពលរដ្ឋ០២នាក់ម្តាយ និងកូន តែប៉ុន្មានម៉ោងក្រោយមកត្រូវបានអនុញ្ញាតអោយត្រឡប់មកផ្ទះវិញ ក្រោយពីបានសួរនាំ និងធ្វើកិច្ចសន្យាឈប់ធ្វើការតវ៉ា *(នៅថ្ងៃទី០៧ ខែកញ្ញា ក្រុមសហគមន៍មានវិវាទដីធ្លីធ្វើការតវ៉ានៅផ្លូវជាតិលេខ ២)* ។ ជម្លោះដ៏រ៉ុាំរ៉ៃ និងគ្មានដំណោះស្រាយច្បាស់លាស់ ០៣ថ្ងៃក្រោយមក នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០២១[1] មានហឹង្សាទ្រង់ទ្រាយធំបានផ្ទុះឡើង រវាងប្រជាពលរដ្ឋម្ចាស់ដីជាង១០០នាក់ និងកម្លាំងសមត្ថកិច្ចចម្រុះជាង៣០០នាក់ ប្រដាប់ដោយខែល-ដំបង បានប្រើអំពើហឹង្សា បាញ់ទឹក បាញ់ឧស្ម័នបង្ហូរទឹកភ្នែកដាក់ក្រុមប្រជាពលរដ្ឋម្ចាស់ដី ក្រោយពេលដែលប្រជាពលរដ្ឋនាំគ្នាដុតសំរាមនៅខាងមុខ រនាំងដែកបិទផ្លូវរបស់សមត្ថកិច្ច ដើម្បីតវ៉ាទាមទារឲ្យសមត្ថកិច្ច បើកផ្លូវអនុញ្ញាតឲ្យពួកគាត់បានចូលទៅមើលដីស្រែក្នុងទីតាំងជម្លោះ ដែលក្រុមហ៊ុនបានឈូសឆាយ-បំផ្លិចបំផ្លាញចោល កាលពីប៉ុន្មានថ្ងៃមុន.....។ បន្ទាប់ពីមានការប៉ះទង្គិចគ្នា កម្លាំងសមត្ថកិច្ចបានចុះចាប់ប្រជាពលរដ្ឋ តាមផ្ទះចំនួន៣០នាក់ និងអ្នកសារព័ត៌មានសហគមន៍ម្នាក់ បញ្ជូនទៅស្នងការខេត្តកណ្តាលដើម្បីសួរនាំ ។ នៅក្នុងពេលចុះចាប់ប្រជាពលរដ្ឋកម្លាំងចម្រុះបានធាក់បំផ្លាញទ្វារ កញ្ចក់ផ្ទះ ម៉ាស៊ីនថតចម្លង និងកាយស្រូវ អង្ករ វាយទាត់ធាក់មនុស្សហើមមុខមាត់ និងខ្លះរហូតដល់ជិតបាក់ដៃ និងដកយកម៉ូតូដែលចតចោលអស់ជាច្រើនគ្រឿង ព្រមទាំងកាត់ផ្តាច់ចរន្តអគ្គីសនី ។ ក្នុងនោះមានប្រជាពលរដ្ឋចំនួន០៩នាក់ បានបញ្ជូនទៅតុលាការចោទប្រកាន់បទ " **ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស ញុះញង់ឲ្យប្រព្រឹត្តិបទឧក្រិដ្ឋជាអាទិ៍ និងប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស** " និងប្រជាពលរដ្ឋចំនួន២១នាក់ បានធ្វើកិច្ចសន្យាឲ្យត្រឡប់មកផ្ទះវិញ នៅរសៀលថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ ។ ពលរដ្ឋម្ចាស់ដីម្នាក់ បានចាត់ទុកទង្វើអាជ្ញាធរខេត្តកណ្តាល ប្រើហឹង្សាដាក់ប្រជាពលរដ្ឋថា ជារឿងអយុត្តិធម៌ ចំពោះប្រជាពលរដ្ឋម្ចាស់ដីជាង៣០០គ្រួសារ ដែលត្រូវបាត់បង់ដីស្រែទៅខាងក្រុមហ៊ុន ហើយថែមទាំងរងការធ្វើបាបពីសំណាក់អាជ្ញាធរទៀត...គាត់បន្ថែមទៀតថា ៖ គេមិនដែលយកក្បាលប្រជាពលរដ្ឋទុកក្នុងខ្លួនគេទេ...ចង់ប្រជាពលរដ្ឋងាប់ម៉េចងាប់ទៅ...នេះហើយអាជ្ញាធរស្រុកខ្មែរ.........ច្បាប់ស្រុកខ្មែរ.....ឲ្យប្រជាពលរដ្ឋគោរពច្បាប់ទៅ គោរពតែប្រជាពលរដ្ឋទៅ...ខ្ញុំថាធ្វើម៉េចធ្វើទៅ...ច្បាប់លើអ្នកឯង...ទោះបីពួកខ្ញុំត្រូវក៏ពួកអ្នកឯងថាខុសដែរ...អ៊ីចឹង! ពួកខ្ញុំវាគ្មានអ្វីនោះទេជាមួយអ្នកឯង គ្មានអ្វីតតាំងទេ។ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំដដែល តុលាការបានសំរេចបានដោះលែងប្រជាពលរដ្ឋទាំង០៩នាក់ ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ បន្ទាប់ពីក្រុមគ្រួសារឪពុកម្តាយពួកគេបានធ្វើលិខិតសុំទោស សារភាពកំហុស យល់ព្រមបញ្ឈប់សកម្មភាពតវ៉ា និងចូលរួមអភិវឌ្ឍជាតិ ។ ពួកគាត់នៅតែមានការភ័យខ្លាច បាក់ស្បាត " អារម្មណ៍របស់ខ្ញុំ-ភ្នែករបស់ខ្ញុំ នៅតែជិតជាមនូវសកម្មភាពដ៏រន្ធត់បំផុតនោះ ដែលកងកម្លាំងប្រដាប់អាវុធច្រើននាក់ចាប់វាយទាត់ធាក់ប្តីរបស់ខ្ញុំផ្ទប់នឹងដី នៅក្នុងបរិវេណមុខផ្ទះរបស់ខ្ញុំ ហើយពួកគេបានចាប់ចងដៃមកក្រោយ បណ្តើរចេញទៅឃុំនៅសាលាខេត្ត២ថ្ងៃ និងដាក់ក្នុងពន្ធនាគារ៧ថ្ងៃ....ខ្ញុំមិនអាចជួយអ្វីបាន.....ទង្វើនេះប្រៀបបានប្តីខ្ញុំប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ ឬដូចសម័យខ្មែរក្រហម " ប្រពន្ធប្រជាពលរដ្ឋម្នាក់ដែលត្រូវបានជាប់ឃុំនិយាយ...ហ៊ឺ! ពិតជាពិបាកណាស់ គេមកយកដីខ្ញុំហើយ វ៉ាយពួកខ្ញុំ ចាប់ពួកខ្ញុំ ឃុំឃាំង ពួកខ្ញុំ ហើយបង្ខំពួកខ្ញុំ

[1] RFA_12-9-2021: https://www.youtube.com/watch?v=tOyVXCL07ac

ឲ្យយល់ព្រមផ្តិតមេដៃឈប់តវ៉ា និងចូលរួមអភិវឌ្ឍជាតិ ទោះបីជាពួកគេបានដឹងយ៉ាងច្បាស់ថា តម្លៃដែលក្រុមហ៊ុនផ្តល់ឲ្យមានការខុសគ្នាច្រើន នឹងតម្លៃទីផ្សាររហូតដល់ជាងដប់ដងឯណោះ!

② **ស្រុកស្អាង៖** ការស្លាប់របស់បុរសម្នាក់ឈ្មោះ ប៊ុន ច័ន្ទសិទ្ធិ មានអាយុ៣៤ឆ្នាំ នាព្រឹកថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ បន្ទាប់ពីបញ្ជូនដល់មន្ទីរពេទ្យជ័យជំនះក្រុងតាខ្មៅ ។ គ្រួសារសពមានការខកចិត្តយ៉ាងខ្លាំងចំពោះអាជ្ញាធរ ដែលមានការយឺតយ៉ាវក្នុងការបញ្ជូនទៅព្យាបាល និងមិនផ្តល់ដំណឹងជុំវិញស្ថានភាពអ្នកជាប់ឃុំ អំឡុងពេលឈឺ នៅក្នុងពន្ធនាគារ ។ ប្រពន្ធជនរងគ្រោះបន្ថែមទៀតថា៖ ការជាប់ពន្ធនាគាររបស់ប្តីលោកស្រីជារឿងអយុត្តិធម៌មួយ ដែលគ្រាន់តែទាមទាររកដំណោះស្រាយបញ្ហាដីធ្លី ជាមួយបុគ្គលឯកជនដែលមិន



ស្គាល់អត្តសញ្ញាណ លោកស្រីមានការឈឺចាប់ជាខ្លាំងដោយសារអាជ្ញាធរមិនបានជួយដោះស្រាយរឿងដីធ្លី ប៉ុន្តែបែរជាចាប់ប្តីលោកស្រីយកទៅដាក់ឃុំឃាំងទាំងអយុត្តិធម៌ រហូតដល់ធ្លាក់ខ្លួនឈឺស្លាប់។ លោកស្រីបន្តទៀតថា៖ ព្រោះដីមួយកន្លែងដែលប្តីខ្ញុំតវ៉ាហ្នឹងគេយកបាត់ហើយ ឥឡូវនៅសល់ដីមួយកន្លែងទៀត ខ្ញុំខ្លាចគ្មានលទ្ធភាពគេយកមួយកន្លែងហ្នឹងបាត់ទៀត មិនដឹងបានអីចិញ្ចឹមកូនទេ រាល់ថ្ងៃជំហរគ្រួសារពឹងលើប្តី គាត់ជាប់ពន្ធនាគារពីរខែខ្ញុំថា ពេលគាត់ចេញមកយើងបានធូរវិញហើយរកលុយបង់សង តែគាត់ទៅរហូត បានអ្នកណាចិញ្ចឹមកូន បានអ្នកណាបង់ធនាគារ ជីវិតទុក្ខជាន់លើទុក្ខ ហើយកូនយំនឹកឪ សម័យកូវីដរកស៊ីចិញ្ចឹមកូនមិនរស់ផង។ ក្រោយពីមានហេតុការណ៍នេះកើតឡើង អាជ្ញាធរខេត្តលើកឡើងថា៖ អាជ្ញាធរ នឹងពិនិត្យមើលករណីជនជាប់ឃុំដោយសារជម្លោះដីធ្លីពីរនាក់ទៀតជាមួយតុលាការ ដើម្បីដោះលែងពួកគេ ប្រសិនបើពួកគេបញ្ឈប់ការតវ៉ា។ **បញ្ជាក់៖** កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ លោក **ប៊ុន ច័ន្ទសិទ្ធិ** និងសកម្មជន០២នាក់ផ្សេងទៀត ត្រូវបានចាប់ និងឃុំខ្លួននៅពន្ធនាគារខេត្ត បន្ទាប់ពីពួកគេចេញមុខតំណាងឲ្យប្រជាពលរដ្ឋជាង១០០គ្រួសារ ដើម្បីការពារដីស្រែចំការទំហំ១៧៥ហិកតា ជាប់ពាក់ព័ន្ធជម្លោះទាមទារដីធ្លីមួយកន្លែងស្ថិតនៅចំណុចអូរសន្ទៃ ភូមិលេខ៤ ឃុំប្រាសាទ ស្រុកស្អាង ។ ស្ត្រីជាភរិយារបស់ប្រជាពលរដ្ឋម្នាក់ក្នុងចំណោមអ្នកត្រូវបានចាប់ខ្លួនទាំងនោះបាននិយាយថា ៖ ខ្ញុំខកចិត្តជាខ្លាំង នេះជារឿងអយុត្តិធម៌ណាស់ ចាប់ប្តីរបស់ខ្ញុំដោយគ្មានដីកា តើប្តីខ្ញុំធ្វើអ្វីខុសបានជាប៉ូលីសមកព័ទ្ធចាប់ប្តីខ្ញុំញាត់ចូលឡានខ្ញុំព្រួយបារម្ភណាស់ សូមដោះលែងប្តីខ្ញុំវិញទៅ ។ ករណីនេះផ្ទុយពីប្រសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល " ចាប់តាមទំនើងចិត្តមានន័យថា ខុសច្បាប់ ហើយមិនមែនគ្រាន់តែខុសច្បាប់ទេ អ្នកចាប់គេត្រូវមានទោសទៀត " ។

③ **ស្រុកអង្គស្នួល ៖** កាន់តែធ្ងន់ធ្ងរជាងនេះទៀត[2] កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ មានករណីគម្រាមគំហែងដោយប្រើកងកម្លាំងប្រដាប់អាវុធបាញ់រះ មកលើប្រជាពលរដ្ឋ តវ៉ារឿងដីធ្លីនៅភូមិអង្គស្រែពោធិ៍ ឃុំទួលព្រិច ស្រុកអង្គស្នួល បណ្ដាលឲ្យប្រជាពលរដ្ឋម្នាក់រងរបួសធ្ងន់ធ្លាយស្មាខាងឆ្វេង[3]។ ដោយសារមិនមានដំណោះស្រាយច្បាស់លាស់នូវជម្លោះដីធ្លីរ៉ាំរ៉ៃមួយនេះ បណ្ដាលឲ្យ ផ្ទុះឡើងជាថ្មីនៅរសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ ឈានដល់ការប្រើអំពើហិង្សាដាក់គ្នា រវាងប្រជាពលរដ្ឋដែលប្រើប្រាស់ដីធ្លីជាយូរមកហើយ និងកងកម្លាំងយោធាដែលការពារដីនៅចំណុចចំការបារាំងនោះ បើតាមការបញ្ជាក់ពីសាលាខេត្តកណ្ដាលដីទំនាស់នេះ មានទំហំ២៨០ហិកតា ជាដីរដ្ឋដែលរដ្ឋាភិបាលគ្រោងរៀបចំមួយផ្នែក សម្រាប់ប្រើប្រាស់ជាប្រយោជន៍លើវិស័យយោធា និងមួយសម្រាប់បរិស្ថាន ( កន្លែងចាក់សម្រាម ) ។ ក្រុមកងកម្លាំងយោធាបានប្រើគ្រឿងចក្រឈូសឆាយព្រៃក និងដីស្រែដែលមិនទាន់មានដំណោះស្រាយនៅឡើយ ។ *ករណីប្រើអំពើហិង្សា បង្ក្រាប បាញ់ប្រហារ មកលើប្រជាពលរដ្ឋម្ចាស់ដីក្នុងរឿងវិវាទដីធ្លីតែងតែកើតឡើងជាញឹកញាប់ ពីសំណាក់កងកម្លាំងប្រដាប់អាវុធ ការពារឲ្យអ្នកមានអំណាច និងក្រុមហ៊ុនឯកជន នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដូចជាករណីបាញ់ប្រជាពលរដ្ឋនៅខេត្តក្រចេះ[4]ឆ្នាំ២០១៨ និងករណីឈូសឆាយផលដំណាំ ដុតបំផ្លាញផ្ទះប្រជាពលរដ្ឋ៣១គ្រួសារ នៅខេត្តក្រចេះ[5] កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥ និងករណីបាញ់ប្រជាពលរដ្ឋនៅឃុំបិទត្រាង[6] ខេត្តព្រះសីហនុ ឆ្នាំ២០១៩។*

**គោលបំណងរបាយការណ៍** ដើម្បីលើកកម្ពស់សិទ្ធិប្រជាពលរដ្ឋ រាល់ករណី ការចាប់ខ្លួន ចោទប្រកាន់ឃុំខ្លួន រឿងវិវាទដីធ្លី របាយការណ៍នេះមានគោលបំណងស្នើរាជរដ្ឋាភិបាល តុលាការគ្រប់ជាន់ថ្នាក់ *បង្អង់បណ្ដឹងអាជ្ញា បញ្ឈប់ការចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួនប្រជាពលរដ្ឋក្នុងរឿងវិវាទដីធ្លីនៅកម្ពុជា និងដាក់ទោសទណ្ឌចំពោះរាល់ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិផលដំណាំប្រជាពលរដ្ឋក្នុងរឿងវិវាទដីធ្លី។*

**ឆ្លើយតបបញ្ហា** ដូចបានរៀបរាប់ខាងលើ តើយើងយល់ឃើញថា តុលាការនៅប្រទេសកម្ពុជា កំពុងតែបន្តចាត់ការលើបណ្ដឹងអាជ្ញាមុន ដោយមានការចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួនប្រជាពលរដ្ឋ នៅក្នុងរឿងវិវាទដីធ្លី? ហើយនីទណ្ឌភាពចំពោះរាល់ការបង្ក្រាបហិង្សាដោយចេតនា ធ្វើឲ្យមានរបួសធ្ងន់ធ្ងរ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិផលដំណាំប្រជាពលរដ្ឋម្ចាស់ដីក្នុងរឿងវិវាទដីធ្លី?

**សារៈសំខាន់** របាយការណ៍នេះគឺ ដើម្បីរួមចំណែកក្នុងការស្វែងរកវិធីសាស្ត្រដោះស្រាយបញ្ហាវិវាទដីធ្លីដ៏រ៉ាំរ៉ៃដោយសន្តិវិធី គ្មានអំពើហឹង្សា និងការរស់នៅក្នុងសង្គមប្រកបដោយសុខដុមរម្យនា ជាពិសេសលើកម្ពស់ការអនុវត្តន៍ច្បាប់ឲ្យមានប្រសិទ្ធិភាពខ្ពស់ ដោយមិនលំអៀង លើកកម្ពស់សិទ្ធិប្រជាពលរដ្ឋ

[2] RFA_9-8-2021: https://streamer1.rfaweb.org/stream/KHM/KHM-2021-0809-1230.mp3
[3] RFA_3-6-2021: https://www.youtube.com/watch?v=k8CxOma4I88
[4] RFA_8-3-2018: https://www.youtube.com/watch?v=zc4pYQEIqK8
[5] RFA_10-9-2015: https://www.youtube.com/watch?v=AlHhL31NQY8
[6] RFA_1-3-2019: https://www.youtube.com/watch?v=clh_KmdW75Q

ដែលធានាដោយរដ្ឋធម្មនុញ្ញ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងបញ្ឈប់រាល់ការចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួនប្រជាពលរដ្ឋម្ចាស់ដីក្នុងរឿងវិវាទដីធ្លីនៅកម្ពុជា ។

**វិធីសាស្ត្រ** របាយការណ៍នេះ បង្ហាញអំពីសិទ្ធិពលរដ្ឋត្រូវបានរំលោភ ការចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួន រឿងវិវាទដីធ្លីនៅប្រទេសកម្ពុជា ដែលផ្តោតសំខាន់លើករណីវិវាទដីធ្លីមានលក្ខណៈធ្ងន់ធ្ងរ ដូចជាករណីគម្រាមកំហែងប្រើហិង្សាបំបាក់ស្មារតី បាញ់បោះ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ផ្ទះសម្បែងផលដំណាំ ចាប់ចង ចោទប្រកាន់ ឃុំខ្លួនភាគីវិវាទ តាមប្រព័ន្ធតុលាការ ដើម្បីបំពេញចិត្តអ្នកមានទ្រព្យ-មានអំណាច។

ការប្រមូលព័ត៌មាន តាមរយៈរបាយការណ៍អង្កេត និងអន្តរាគមន៍របស់មន្ត្រីសម្របសម្រួលប្រចាំការិយាល័យ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)ទាំង១៧ខេត្ត-ក្រុង ដែលមានវិសាលភាពទូទាំង២៥ខេត្ត-ក្រុង ដោយឆ្លងកាត់ការវិភាគ និងបញ្ចូលទិន្នន័យនៅស្នាក់ការកណ្តាលភ្នំពេញ ព្រមទាំងចុះទៅពិនិត្យប្រមូលព័ត៌មានបន្ថែមដល់ទីកន្លែងកើតហេតុដោយផ្ទាល់ ពីសំណាក់មន្ត្រីសរសេររបាយការណ៍ ។ ព័ត៌មានប្រមូលបានមួយចំនួន បានយកមកផ្ទៀងផ្ទាត់ជាមួយនិងព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយដែលអាចទុកចិត្តបាន ហើយព័ត៌មានទាំងនោះ បានដកស្រង់សំដីរបស់អ្នកនាំពាក្យ ថ្នាក់ដឹកនាំ និង/ឬ បុគ្គលិករបស់សមាគមអាដហុកផ្តល់ឲ្យ ។

ការវិភាគព័ត៌មាន ត្រូវបានធ្វើការវិភាគតាមបែបគុណវិស័យ៨០% និងបរិមាណវិស័យ២០% ប្រើសំណាករបាយការណ៍អង្កេតជាក់ស្តែង ដែលប្រមូលបានតាមការិយាល័យប្រចាំខេត្តនិមួយៗ ។

ការសរសេររបាយការណ៍ ជាលក្ខណៈវិភាគ និងសង្ខេបអត្ថន័យសំខាន់ៗពេញលេញ បង្ហាញពីគោលរឿងនៃបញ្ហា មូលហេតុដែលនាំឲ្យមានវិវាទ និងនីតិវិធីដោះស្រាយ របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ហើយចំពោះរបាយការណ៍ករណីវិវាទពេញលេញទាំងស្រុងដែលមានតម្កល់ទុកនៅការិយាល័យកណ្តាលរបស់សមាគមអាដហុក ព្រមទាំងរក្សាទុកក្នុងទិន្នន័យសុវត្ថិភាពអេឡិចត្រូនិច ។

## II. ប្រវត្តិកម្មសិទ្ធិលើដីធ្លី

សាវតារដីធ្លីនៅកម្ពុជា ជាផ្នែកមួយនៃការបង្ហាញឲ្យឃើញអំពីគោលនយោបាយ និងរបៀបនៃការគ្រប់គ្រងដីធ្លីនៅតាមសម័យកាលនិមួយៗដូចជា៖ **ខ្មែរនៅសម័យបុរាណ**ព្រះមហាក្សត្រគឺជាម្ចាស់ផែនដី ម្ចាស់ដីធ្លី ម្ចាស់លើជោគវាសនារបស់ប្រជារាស្ត្រទាំងអស់ ហើយនៅក្នុងសម័យកាលនោះដែរ សិទ្ធិកាន់កាប់-ប្រើប្រាស់ដីធ្លីមានលក្ខណៈខុសៗគ្នាអាស្រ័យទៅតាមវណ្ណៈនិមួយៗ និងតាមរយៈការកាប់ទន្រ្ទានកាន់កាប់-គ្រប់គ្រង ហើយដីធ្លីដែលបានកាន់កាប់-គ្រប់គ្រងនោះ អាចផ្ទេរបានតាមរយៈសន្តតិកម្ម ឬមរតកសាសន៍ ប៉ុន្តែសិទ្ធិនោះអាចត្រូវបាត់បង់ទៅវិញ ប្រសិនបើដីនោះបានបោះបង់ចោលលែងប្រើប្រាស់រយៈពេលលើសពីបីឆ្នាំជាប់ៗគ្នា ។ ចំពោះពន្ធដារត្រូវបានកំណត់ប្រមូលទៅតាមទិន្នផលដំណាំដែលទទួលបាន ។ **នៅសម័យអាណានិគមបារាំង** ព្រះមហាក្សត្រលែងមានសិទ្ធិធ្វើជាម្ចាស់ផ្តាច់មុខលើដីធ្លីទាំងអស់ដូចនៅសម័យបុរាណទៀតហើយ ហើយទន្ទឹមគ្នានោះ កម្មសិទ្ធិដីឯកជនត្រូវបានលេចរូបរាងប្រាកដឡើង ក្នុងប្រទេសកម្ពុជាតាមរយៈក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ។ ផ្ទុយទៅវិញ នៅ**សម័យកម្ពុជាប្រជាធិបតេយ្យ** ច្បាប់នានាត្រូវបានលុបបំបាត់ចោលរួមទាំងច្បាប់ស្តីពី សិទ្ធិលើទ្រព្យ

សម្បត្តិ និងកម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានហាមឃាត់ ហើយគ្រប់កម្មវត្ថុនៃអចលនវត្ថុទាំងអស់ដាក់ជាកម្មសិទ្ធិរួម-កម្មសិទ្ធិសមូហភាព ។ ឈានចូលដល់ **សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា** ច្បាប់-ក្រមខណ្ឌគតិយុត្តិ-រចនាសម្ព័ន្ធត្រូវបានរៀបចំឡើងវិញ ក្នុងនោះរួមទាំងសិទ្ធិកម្មសិទ្ធិអចលនវត្ថុដូចជា អនុក្រឹត្យលេខ២៥ ឆ្នាំ១៩៨៩ បានទទួលស្គាល់សិទ្ធិកម្មសិទ្ធិលើផ្ទះសម្បែង សិទ្ធិភោគៈលើដីដាំដំណាំដែលច្បាប់បានកំណត់នូវទំហំយ៉ាងច្រើនត្រឹម៥ហិចតា ករណីភោគីមានបំណងគ្រប់គ្រងដីលើសពី៥ហិកតាឡើង ជាសិទ្ធិរបស់រដ្ឋាភិបាលក្នុងការផ្តល់ជូន តាមលក្ខណៈជាដីសម្បទាន តាមរយៈក្រសួងកសិកម្ម ។ ហើយនៅ**សម័យរដ្ឋកម្ពុជា** ច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានអនុម័ត ក្នុងគោលបំណងជានាសិទ្ធិអចលនវត្ថុ សិទ្ធិកម្មសិទ្ធិ សិទ្ធិភោគៈ និងសិទ្ធិទាំងឡាយណាដែលពាក់ព័ន្ធដីធ្លីក្នុងប្រទេសកម្ពុជា ។ មកដល់**សម័យព្រះរាជាណាចក្រកម្ពុជា** យោងតាមមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានទទួលស្គាល់នូវសិទ្ធិកម្មសិទ្ធិឯកជនលើអចលនវត្ថុ និងចលនវត្ថុ ។ ច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងបន្ថែមការផ្តល់នូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិដីធ្លី ដែលមានតម្រូវការចាំបាច់បំផុត ។ ម៉្យាងទៀតអនុក្រឹត្យលេខ១៤៦ ឆ្នាំ២០០៥ បានអនុញ្ញាតអោយរដ្ឋាភិបាលធ្វើការផ្តល់សិទ្ធិលើដីធ្លីតាមរយៈដីសម្បទានសេដ្ឋកិច្ច ឬដីសម្បទានសង្គមកិច្ច ។

## III. មូលហេតុការចាប់ខ្លួនចោទប្រកាន់វិវាទដីធ្លី

មានកត្តាធំមួយចំនួនដែលបណ្តាលឲ្យមានការចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួនប្រជាពលរដ្ឋម្ចាស់ដីក្នុងរឿងវិវាទដីធ្លីនៅកម្ពុជាដែលបង្ហាញអំពីភាពមិនប្រក្រតីក្នុងការអនុវត្តច្បាប់ និងសកម្មភាពរំលោភសិទ្ធិប្រជាពលរដ្ឋភាគីទំនាស់ដែលមានវិវាទជាមួយបុគ្គលមានអំណាច-អ្នកមានទ្រព្យ(ឧកញ៉ា) - ក្រុមហ៊ុនឯកជន តាមរូបភាពគម្រោងអភិវឌ្ឍន៍ ប្រើកម្លាំងប្រដាប់អាវុធ ដើម្បីបំបាក់ស្មារតី សម្លុត-គម្រាមកំហែង-ចាប់ចង តាមរូបភាពចោទប្រកាន់-ឃុំខ្លួន តាមរយៈប្រព័ន្ធតុលាការ ហើយបង្ខំឲ្យសារភាព ឬសរសេរលិខិតសុំទោស និងធ្វើកិច្ចសន្យា ដើម្បីជាថ្នូរនឹងការដោះលែងឲ្យមានសេរីភាព ។ ឆ្លងតាមបទពិសោធន៍ការងារលើវិស័យសិទ្ធិមនុស្សដីធ្លីរបស់សមាគមអាដហុក អាចកំណត់ឬសគល់ នៃមូលហេតុដែលបណ្តាលឲ្យមានការចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួន ប្រជាពលរដ្ឋភាគីក្នុងរឿងវិវាទដីធ្លីនៅកម្ពុជាគឺ: ១.បំបាក់ស្មារតី ប្រជាពលរដ្ឋភាគីវិវាទ លែងហ៊ានប្រើសិទ្ធិក្នុងការស្វែងរកយុត្តិធម៌ - ២.ឥទ្ធិពលអ្នកមានអំណាច-មានទ្រព្យ(ឧកញ៉ា)- ៣. ការអនុវត្តច្បាប់មិនពេញលេញ និងលំអៀង និង ៤. ខ្វះការពិគ្រោះយោបល់ជាសាធារណៈនៃគម្រោងអភិវឌ្ឍន៍៖

### ១. បំបាក់ស្មារតី

ទង្វើទាំងនេះ ធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ស្មារតីសតិអារម្មណ៍ មិនត្រឹមតែជនរងគ្រោះម្ចាស់ដីផ្ទាល់ក្នុងរឿងជម្លោះដីធ្លីប៉ុណ្ណោះទេ ថែមទាំងជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេសមានការភ័យខ្លាច-សុបិន្តអាក្រក់ និងបាក់ស្បាតមិនហ៊ានប្រើសិទ្ធិរបស់ខ្លួនក្នុងការតតាំងដោយសន្តិវិធី ដើម្បីទាមទារអ្វីដែលជារបស់ខ្លួនមកវិញ ពីព្រោះសំណុំរឿងភាគច្រើនពួកគាត់បានប្រែក្លាយជាចុងចម្លើយទៅវិញ ដែលតែងតែត្រូវបានចោទប្រកាន់ពីបទ៖ **ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស ពីបទញុះញង់ឲ្យប្រព្រឹត្តិបទឧក្រិដ្ឋជាអាទិ៍ ពីបទ**

**ប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោសជាដើម** ។ លើសពីនេះទៀត ដោយចេតនាពន្យាពេល និងភាពយឺតយ៉ាវក្នុងការដោះស្រាយវិវាទដីធ្លីដ៏រ៉ាំរ៉ៃ នាំឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចគ្រួសារប្រជាពលរដ្ឋម្ចាស់ដីដែលជាជនរងគ្រោះ...ដូចជា មានករណីមួយចំនួន បានកើតឡើងនៅខេត្ត៖

**ខេត្តត្បូងឃ្មុំ៖** ជម្លោះដីធ្លីមានលក្ខណៈធ្ងន់ធ្ងរ រហូតដល់មានប្រើគ្រឿងចក្រឈូសឆាយ ចំការស្រែស្រូវដំឡូង ដំណាំប្រជាជាកសិករ គម្រាមកំហែងបាញ់រះ ប្រើដំបងឆក់មកលើស្ត្រីកូនខ្ចី ចាប់ខ្លួន-ឃុំខ្លួនសកម្មជនដីធ្លីដាក់ពន្ធនាគារ ។







ជម្លោះរ៉ាំរ៉ៃនេះបានកើតឡើងនៅភូមិបុស្សស្នោ និងភូមិស្រែប្រាំង ឃុំត្រពាំងព្រីង ស្រុកតំបែរ រវាងប្រជាពលរដ្ឋចំនួន១០៩គ្រួសារ ជាមួយក្រុមហ៊ុនចិន តវ៉ាទាមទារដីទំហំ១,២៣០ហិចតា ។ ភ្លាមៗនោះ អាជ្ញាធរចាប់ខ្លួនប្រជាសហគមន៍២០នាក់[7] ក្រោយពីពួកគេចេញមុខតវ៉ាប្រឆាំង គ្រឿងចក្ររបស់ក្រុមហ៊ុនចិន មិនឲ្យចូលទៅឈូសឆាយដីស្រែចំការរបស់ពួកគេ ហើយចាប់ពីពាក់កណ្តាលឆ្នាំ២០២០ដល់ឆមាសទី២ ឆ្នាំ២០២១ តុលាការសម្រេចផ្តន្ទាទោសប្រជាពលរដ្ឋម្ចាស់ដីចំនួន៤០នាក់ ពីបទ " សមគំនិតក្នុងអំពើញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងពីបទកំហែងយកមានស្ថានទម្ងន់ទោស ដោយប្រើប្រាស់អាវុធ " តាមមាត្រា២៩ និង៤៩៥ ដោយក្នុងនោះអ្នកខ្លះជាប់ពន្ធនាគារចន្លោះពី១ឆ្នាំ រហូតដល់៧ឆ្នាំ និងសំណង់ជាប្រាក់រាប់លានរៀល។ នៅពាក់កណ្តាលខែតុលា[8] ឆ្នាំ២០២១ តំណាងសហគមន៍ម្នាក់ (លោកសែម សាង) ត្រូវបានដោះលែងឲ្យមានសេរីភាព ក្រោយពីបានអនុវត្តទោសគ្រប់ពីរឆ្នាំ " ខណៈតំណាងសហគមន៍ពីរនាក់ទៀត កំពុងបន្តអនុវត្តទោសនៅពន្ធនាគារខេត្តនៅឡើយទេ " ។ លោកមានប្រសាសន៍ថា ៖ ការចាប់ខ្លួនលោកកាលពីខែតុលា ឆ្នាំ២០១៩ ហើយត្រូវតុលាការបានកាត់ទោសឲ្យជាប់ពន្ធនាគារ២ឆ្នាំនោះ គឺជារឿងឈឺចាប់ និងអយុត្តិធម៌បំផុត ដែលគ្រាន់តែចេញតវ៉ាទាមទាររកដំណោះស្រាយដីធ្លីដោយសន្តិវិធី ពីអាជ្ញាធរ និងក្រសួងដែនដី ។ ខ្ញុំសូមឲ្យសម្តេចនាយករដ្ឋមន្ត្រីជួយ

---

[7] RFA_5-8-2020: https://www.youtube.com/watch?v=3mt88MuoHJ4 and VOD_3-8-2020: https://www.youtube.com/watch?v=M70knQQxMWc and VOD_15-8-2020: https://www.youtube.com/watch?v=GjMp36yahoU

[8] RFA_18-10-2021: https://www.rfa.org/khmer/news/land/representative-of-sre-prang-community-commit-to-demanding-land-dispute-resolution-after-released-from-jail-10182021170150.html

រកភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ ហើយនឹងសូមឲ្យសម្តេច បង្កើតគណៈកម្មការចម្រុះ ហើយរើកញែករកអ្នកពាក់ព័ន្ធ ដែលលក់ដីទៅឲ្យក្រុមហ៊ុន ។ មិនមែនប្រជាពលរដ្ឋអ្នកលក់ទេ គឺមានតែអាជ្ញាធរ គាត់មានសិទ្ធិលក់ដាង ។ ហើយនឹងសូមកុំឲ្យមានការចាប់ចង ឬក៏គំរាមកំហែង ចាប់ដាក់គុក ឬប្រើអំពើហិង្សាលើពលរដ្ឋ ។ ខ្ញុំសូមទទូចឲ្យរកភាពយុត្តិធម៌ជូនប្រជាពលរដ្ឋតែម្តង » ។

លោកបានរៀបរាប់អំពីផលវិបាកអំឡុងពេលរស់នៅក្នុងពន្ធនាគារ[9] ដូចជាបន្ទប់ចង្អៀត (មួយបន្ទប់៤០នាក់) ម្ហូបអាហារ-ទឹកស្អាតមិនគ្រប់គ្រាន់ ខ្វះអនាម័យ ងាយកើតជម្ងឺកមរមាស់ ។ ចំណែកក្រុមគ្រួសារកាន់តែមានការលំបាកខ្លាំង ដែលប៉ះពាល់ដល់ស្ថានភាពរស់នៅប្រចាំថ្ងៃដូចជា ប្រពន្ធខ្ចីលុយជានាគារ កូនស្រីឈប់រៀន កូនប្រុសធ្វើចំណាកស្រុក ។ លើសពីនេះទៅទៀត អ្វីដែលធ្វើឲ្យគាត់កាន់តែមានសតិអារម្មណ៍ខ្លាំងនោះ គឺ ការនៅតែបន្តតាមដាន ឃ្លាំមើលពីសំណាក់អាជ្ញាធរ ក្រោយពីលោកត្រូវបានដោះលែងឲ្យមានសេរីភាពចេញពីពន្ធនាគារ ។ គាត់បានបន្ថែមទៀតថា ការបាត់បង់ដីមិនអាចធ្វើស្រែចំការបាន នាំឲ្យប្រជាពលរដ្ឋរងគ្រោះក្នុងសហគមន៍ស្រែប្រាំងប្រហែល៩០ភាគរយ ចំណាកស្រុកទៅធ្វើសំណង់ ឬស៊ីឈ្នួលគេនៅខេត្តផ្សេងៗ ដើម្បីរកចំណូលមកផ្គត់ផ្គង់ជីវភាពគ្រួសារ។

ជនរងគ្រោះម្ចាស់ដីមួយចំនួនដោយមានការភ័យខ្លាច ក្រោយពីមានការគម្រាមកំហែង បំបាក់ស្មារតី (*ជាពិសេសតាមរយៈដាក់អោយជាប់បណ្តឹងអាជ្ញាដែលស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ "ព្យួរទោសបណ្តោះអាសន្ន"*) និងមានការលួងលោមផង ពួកគាត់បានសម្រេចចិត្តមិនបន្តការចូលរួមនីតិវិធីបណ្តឹងតទៅទៀត ។ លើសពីនេះទៀត យើងសង្កេតឃើញក្នុងអំឡុងពេលសវនាការរឿងក្តីនេះ ឃើញមានសមត្ថកិច្ចជិត២០នាក់ នៅខាងមុខបរិវេណតុលាការ គោលបំណងតាមឃ្លាំមើលសាច់ញាតិ និងប្រជាពលរដ្ឋគាំទ្រ បុគ្គលិកអង្គការសង្គមស៊ីវិល ជាពិសេសមានអ្នកឈរមោត់ច្រកចេញចូលចាំថតរូបអ្នកចូល-ចាំឃ្លាំមើលតុលាការ ។ ទង្វើទាំងនេះ ជាការបំបាក់ស្មារតី មិនត្រឹមតែជនរងគ្រោះដីធ្លីប៉ុណ្ណោះទេ សូម្បីតែសាច់ញាតិរបស់ពួកគេ អ្នកចូលរួមមកពីអង្គការជាតិ អង្គការអន្តរជាតិ និងសកម្មជនផ្សេងទៀតដែលមករងចាំឃ្លាំមើលតុលាការ ក៏មានការបារម្ភផងដែរ ។

[9] ការធ្វើសម្ភាសន៍ផ្ទាល់ជាមួយលោកសែមសាង នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១

**ខេត្តបន្ទាយមានជ័យ៖** ជម្លោះដីធ្លីរវាងអ្នកមានទ្រព្យ(ឧកញ៉ា) រំលោភបំពានយកដីប្រជាពលរដ្ឋ



ចំនួន ២៤៦គ្រួសារ មានទំហំ១,៣៥០.៥០ហិចតា ស្ថិតនៅភូមិថ្នល់បត់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ។ នៅក្នុងរឿងនេះ មនុស្ស០៤នាក់តំណាងឲ្យប្រជាសហគមន៍រងគ្រោះ បានក្លាយជាចុងចម្លើយ ហើយ ត្រូវកោះហៅទៅបំភ្លឺនៅតុលាការ ក្រោមការចោទប្រកាន់ពីបទ " ហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត " ។ ម្នាក់ក្នុងចំណោមអ្នកទាំង០៤ បាននិយាយថា៖ " អ្នកដែលប្តឹងខ្ញុំបាទទៅតុលាការនោះ ក្នុងគោលបំណង យកដីរបស់ខ្ញុំបាទ ដែលដីនេះជាដីរបស់ខ្ញុំបាទ "។

**ខេត្តព្រះសីហនុ៖** ការប្រើកម្លាំងប្រដាប់អាវុធចម្រុះ រួមទាំងគ្រឿងចក្រ ចុះទៅរុះរើបំផ្លាញ លំនៅដ្ឋានប្រជាពលរដ្ឋចំនួនពីរលើកផ្ទួនៗ ក្នុងឆ្នាំ២០២០ ដែលនាំឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ ព្រមទាំងមានចាប់ខ្លួន-ឃុំខ្លួន ប្រជាពលរដ្ឋជាច្រើននាក់ដូចជាៈ **លើកទី១** ចាប់ខ្លួនពលរដ្ឋចំនួន២១នាក់ហើយបន្ទាប់ពីការសាកសួរ បានដោះលែងឲ្យត្រឡប់ទៅផ្ទះចំនួន១៨នាក់ និង០៣នាក់ដាក់ឲ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ និង **លើកទី២** បានចាប់ខ្លួនប្រជាពលរដ្ឋ០៧នាក់[10] ហើយនៅថ្ងៃបន្ទាប់ទៀត ប្រជាពលរដ្ឋ០៤នាក់ទៀត ត្រូវបានចាប់ខ្លួនបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារក្រោយពីបានឈូសឆាយផ្ទះសម្បែង - ផលដំណាំប្រជាពលរដ្ឋអស់រលីង ព្រមទាំងដាក់សមត្ថកិច្ចហាមឃាត់ការចេញចូលតំបន់នោះទៀត ។ ជនជាប់ចោទក្នុងរឿងវិវាទដីធ្លីនេះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី០១ឆ្នាំ ដល់០៧ឆ្នាំ និងពិន័យជាប្រាក់ចន្លោះពី១៥លានរៀល ទៅ៧០លានរៀល ។ វិវាទដីធ្លីនេះ កើតឡើងនៅតំបន់ឧទ្យានជាតិរាម ចំណុចក្បាលព្រែកកោះខ្យង ស្ថិតនៅភូមិស្មាច់ដែង ឃុំរាមស្រុកព្រៃនប់មានទំហំដីសរុបចំនួន







[10] CPC New_17-01-2020: https://www.youtube.com/watch?v=NhbqP7h4dts

៣០០ហិចតា ប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន១៣៤គ្រួសារ ជាមួយក្រុមហ៊ុនឯកជនដែលមានទំនាក់ទំនងស្និទ្ធនឹងអ្នកមានអំណាច ក្រោមរូបភាពរដ្ឋ ធ្វើអនុប្រយោគជាលក្ខណៈសម្បទានសេដ្ឋកិច្ច ។

**ខេត្តកំពង់ស្ពឺ៖** មានវិវាទដីធ្លីធំៗ បានកើតឡើងគួរឲ្យកត់សំគាល់ដែលបានអូសបន្លាយរហូតមកដល់ឆ្នាំ២០២១នេះ ដោយមិនរាប់បញ្ចូលករណីជម្លោះដីធ្លីហិង្សារវាងកម្លាំងសមត្ថកិច្ចជាង៣០០នាក់ បាញ់គម្រាម ប្រជាពលរដ្ឋប្រហែល២០០នាក់ ដែលព្យាយាមការពារប្រឆាំងនឹងការអនុវត្តន៍សាលដីកាតុលាការកំពូល ដើម្បីប្រគល់ដីទៅឲ្យក្រុមហ៊ុនឈ្នះក្តី ក្រោមពាក្យស្លោក " **ស៊ូស្លាប់ដើម្បីការពារដីស្រែ** " " **ស៊ូស្លាប់ដើម្បីរស់** " នៅឃុំភ្នំតូច ស្រុកឧត្តុង្គ[11] គឺ៖

① **ស្រុកឱរ៉ាល់:** នាពាក់កណ្តាលឆ្នាំ២០២១ សមត្ថកិច្ចចម្រុះ រួមជាមួយមេការក្រុមហ៊ុន HLH ចំនួនប្រហែល៥០នាក់ បានធ្វើការរុះរើ ដុតបំផ្លាញផ្ទះសម្បែង ផលដំណាំរបស់ប្រជាពលរដ្ឋ ដែលបានចូលកាន់កាប់រស់នៅលើដីនោះអស់រយៈពេលជាង១០ឆ្នាំ (ចាប់តាំងពីឆ្នាំ២០១១) ដែលជាង៨០% គឺជាប្រជាពលរដ្ឋក្រីក្រគ្មានដីធ្លីផ្ទះសម្បែង ។ វិវាទដីធ្លីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ស្ថិតនៅក្នុងភូមិពោធិ៍មាស ឃុំត្រពាំងជោ មានផ្ទៃដីទំហំជិត១០០ហិកតា រវាងក្រុមហ៊ុន HLH ជាមួយប្រជាពលរដ្ឋ១៣០គ្រួសារ។

② **ស្ទឹងប្រាល:** វិវាទដីធ្លី ដែលឈានដល់ក្រុមយោធាប្រើអំពើហឹង្សា ធ្វើការគម្រាមកំហែង និងដុតបំផ្លាញផ្ទះសម្បែង ផលដំណាំរបស់ប្រជាពលរដ្ឋ។ ជម្លោះនេះ បានកើតឡើងរវាងប្រជាពលរដ្ឋ៦០គ្រួសារ ជាមួយយោធាអភិវឌ្ឍន៍ស្ទឹងប្រាល ដែលមានដីទំហំជាង៩០ហិចតា។





③ **ស្រុកឱរ៉ាល់:** ជម្លោះរ៉ាំរ៉ៃបានកើតឡើងតាំងពីឆ្នាំ២០០៥ បន្តរហូតដល់បច្ចុប្បន្ន ហើយករណីនេះ តុលាការបានធ្វើការចោទប្រកាន់ ចាប់ខ្លួន និងឃុំខ្លួនប្រជាពលរដ្ឋ ជាបន្តបន្ទាប់រហូតដល់៣៨នាក់ ដោយចោទពីបទ " **ធ្វើអោយខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងរំលោភកាន់កាប់អចលនវត្ថុរបស់អ្នកដទៃ** " ក្រោយពីមានបណ្តឹងរឿងវិវាទដីធ្លី ជាមួយបុគ្គលមានអំណាចជាយោធា ស្ថិតនៅភូមិតាំងស្រឹង ឃុំសង្កែសាទប ។ ឆ្នាំ២០០៥ មាន០៨នាក់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ និង២១នាក់ ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារ០១ឆ្នាំ ព្យួរសាកល្បង០៥ឆ្នាំ និងសំណងជាប្រាក់៥០លាន

[11] RFA_9-9-2014: https://www.youtube.com/watch?v=IvXMj-wMQOA

រៀល និងបន្ទាប់ទៀតនៅឆ្នាំ២០១៨ ចោទ០៩នាក់ ឃុំខ្លួនម្នាក់ និង០៨នាក់ទៀត ដាក់ឲ្យស្ថិតនៅក្រៅឃុំបណ្ដោះអាសន្ន ។

④ **ស្រុកថ្ពង:** វិវាទដីធ្លីទំហំ៨,៣៤៣ហិកតា ជាមួយក្រុមហ៊ុនសូហ្គី និងប្រជាពលរដ្ឋ១០០០គ្រួសារ ស្ថិតនៅភូមិអូអង្គុំ ឃុំអមលាំង ។ ក្នុងអំឡុងពេលមានវិវាទក្រុមហ៊ុន បានប្រើគ្រឿងចក្រឈូសឆាយផលដំណាំប្រជាពលរដ្ឋ ហើយថែមទាំងប្ដឹងតំណាងប្រជាពលរដ្ឋចំនួន១១នាក់ ។ ក្រោយមកតុលាការបានចេញដីកាចាប់ខ្លួនតំណាងប្រជាពលរដ្ឋចំនួន ០២នាក់ ដាក់ពន្ធនាគារ.......កត្តានេះហើយ ធ្វើឲ្យ



ប្រជាពលរដ្ឋរងគ្រោះរាប់រយគ្រួសារកើតទុក្ខមិនសុខចិត្ត បាននាំគ្នាធ្វើការតវ៉ាបិទផ្លូវជាតិលេខ៤ ដើម្បីស្នើសុំអោយអាជ្ញាធររកដំណោះស្រាយ និងដោះលែងតំណាងរបស់ពួកគេ២នាក់នោះមកវិញ ។

**ខេត្តសៀមរាប៖** ដោយភាពភ័យខ្លាចប្រជាពលរដ្ឋម្ចាស់ដី មិនហ៊ានធ្វើការតវ៉ា ដើម្បីទាមទាររកយុត្តិធម៌ក្រោយអាជ្ញាធរខេត្ត បានចាប់សកម្មជនដីធ្លីម្នាក់ដាក់ពន្ធនាគារនៅខែមីនា ឆ្នាំ២០២១ ជាប់ពាក់ព័ន្ធការតវ៉ារឿងដីធ្លីទំហំ៣០ហិកតា ស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ។

នៅឯស្រុកស្វាយលើ ឃុំកន្ទួត ភូមិរុងរឿង មានវិវាទដីធ្លី ដែលរំលោភដោយអ្នកមានអំណាចមន្ត្រីយោធាស័ក្ដធំបានប្រើកម្លាំងទាហានអង្គភាពវរៈសេនាធំលេខ២៦៤ ចំណុះកងពលលេខ៦ចំនួន ១០នាក់ មានកាំភ្លើងគ្រប់ដៃ បានបណ្ដេញឲ្យប្រជាពលរដ្ឋចេញពីដីជាបន្ទាន់ មិនឲ្យបន្តបង្កបង្កើនផលទៀតទេ ។ ហើយមួយរយៈក្រោយមក កម្លាំងយោធាបានប្រើគ្រឿងចក្រ០៣គ្រឿង ឈូសឆាយបំផ្លាញផលដំណាំស្វាយចន្ទី ដំឡូង ប្រជាពលរដ្ឋអស់ជាង១០ហិចតា ។បន្ទាប់ពីប្រជាពលរដ្ឋ០៤គ្រួសារ បានដាក់ពាក្យបណ្ដឹងទៅក្រសួងការពារជាតិ នៅពាក់កណ្ដាលឆ្នាំ២០២១ មេភូមិរុងរឿងបានបញ្ជាក់ថា ដីទំនាស់មិនមានជាប់ពាក់ព័ន្ធដីរបស់គ្រួសារកងទ័ពទេ ។ ដូច្នេះការចោទប្រកាន់ថា ប្រជាពលរដ្ឋរំលោភយកដីគ្រួសារកងទ័ពជាការមិនពិតទេ...តើការបំផ្លាញផលដំណាំស្វាយចន្ទី ដំឡូងរបស់ប្រជាពលរដ្ឋ នរណាជាអ្នកទទួលខុសត្រូវចំពោះទង្វើនេះ?

**ខេត្តកោះកុង** ការប្រើប្រព័ន្ធតុលាការ ដើម្បីបំបាក់ស្មារតីប្រជាពលរដ្ឋម្ចាស់ដី លែងហ៊ានប្រើសិទ្ធិក្នុងការស្វែងរកយុត្តិធម៌ដល់ក្រុមគ្រួសារ និងសហគមន៍របស់ពួកគាត់ផ្ទាល់ដូចជា៖ នៅក្នុងខែកក្កដា ឆ្នាំ២០២១ តុលាការបានចោទប្រកាន់ និងកោះហៅតំណាងសហគមន៍ដីធ្លី១០នាក់ នៅជីខលើ សួរនាំពីមូលហេតុការជួបជុំធ្វើសកម្មភាព នាំឲ្យប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ ក្រោយពីប្រជាសហគមន៍ ធ្វើ

ការតវ៉ានៅភ្នំពេញ។ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១[12]តុលាការបានបន្តកោះហៅតំណាងសហគមន៍ម្នាក់ ( ខណៈលោកស្រីទើបសម្រាល កូនបាន២០ថ្ងៃ ) ឲ្យចូលខ្លួនតាមបណ្តឹងរបស់លោកឧកញ៉ា ហេងហ៊ុយ ។ លោកស្រីមានប្រសាសន៍ថា៖ ជារឿងអយុត្តិធម៌ចំពោះពលរដ្ឋម្ចាស់ដីដែលត្រូវបាត់បង់ដីស្រែចម្ការមិនទទួលដំណោះស្រាយ ហើយត្រូវជាប់បណ្តឹងនៅតុលាការថែមទៀត ។ ករណីវិវាទដីធ្លីកើតឡើងរយៈពេលមួយទសវត្សកន្លះ រវាងប្រជាពលរដ្ឋ១៩៧គ្រួសារ ជាមួយក្រុមហ៊ុនហេងហ៊ុយអភិវឌ្ឍន៍ នៅដីខលើ ស្រុកស្រែអំបិល ។





ដោយសារតែ មិនមានដំណោះស្រាយសមរម្យ និងអូសបន្លាយពេលយូរនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១[13] ប្រជាពលរដ្ឋប្រមាណ៧០០នាក់ មកពីសហគមន៍មានជម្លោះដីធ្លីចំនួន៧ ដែលមានក្រុមប្រជាពលរដ្ឋ ដែលមានជម្លោះដីធ្លីជាមួយក្រុមហ៊ុនចិន យូញៀន ឌីវិឡប់មិនគ្រុប (UDG) ក្រុមហ៊ុនស្ករអំពៅរបស់ឧកញ៉ា លី យ៉ុងផាត់ និងក្រុមហ៊ុនហេងអភិវឌ្ឍន៍របស់ឧកញ៉ា ហេង ហ៊ុយ ក្នុងខេត្តកោះកុង ប្រមូលផ្តុំគ្នាឈរលើកបដា រូបថតលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងភរិយា នៅមុខសាលាខេត្តកោះកុង នៅថ្ងៃទី២៤ ខែវិច្ឆិកា ២០២១ ដើម្បីស្នើសុំឲ្យអាជ្ញាធរពន្លឿនដំណោះស្រាយវិវាទដីធ្លីជូនពួកគាត់ ។

**ខេត្តឧត្តរមានជ័យ** តុលាការបានចេញដីកាបង្គាប់អោយពលរដ្ឋ ចំនួន១៣នាក់ ចូលខ្លួនឆ្លើយបំភ្លឺជុំវិញសំណុំរឿងកាប់រានដីព្រៃនៅ ភូមិស្រះកែវ ឃុំពង្រ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ[14]។

**ភ្នំពេញ** កាលពីថ្ងៃទី០២ ខែសីហាឆ្នាំ២០២១ អាជ្ញាធរខណ្ឌឫស្សីកែវ៥០នាក់[15] ប្រើគ្រឿងចក្រឈូសឆាយ និងរុះរើផ្ទះប្រជាពលរដ្ឋនៅសហគមន៍បឹងឈូកអា ១៥ខ្នង នៅភូមិបឹងឈូក សង្កាត់គីឡូលេខ៦ ខណ្ឌឫស្សីកែវ ។ ប្រជាពលរដ្ឋរងគ្រោះបានចាត់ទុកសកម្មភាពនេះ ជាការធ្វើទុក្ខបុកម្នេញប្រជាជនស្លូតត្រង់ ដើម្បីយកដីអោយក្រុមហ៊ុនឯកជន ខណៈពួកគាត់បានរស់នៅអស់រយៈពេលជាង២០មកហើយ វាជារឿង៖ អយុត្តិធម៌សម្រាប់ពួកខ្ញុំដែលជាប្រជាពលរដ្ឋខ្មែរណាស់ ដែលរស់នៅលើទឹកដីខ្មែរផ្ទះសម្បែងខ្លួនឯង ត្រូវគេដេញចេញដោយគ្មានសំណងសងពួកខ្ញុំអយុត្តិធម៌ណាស់ ពួកខ្ញុំទទួលយកមិនបានទេ ទាំងសម័យកូវីដខ្ញុំរកអីអត់បាន ហើយមកដេញពួកខ្ញុំចេញទៀត ឲ្យខ្ញុំរស់នៅរបៀបណាខ្ញុំ

[12] RFA 03-11-2021 https://www.rfa.org/khmer/news/land/citizen-in-land-dispute-with-duke-heng-huy-who-gave-birth-one-month-ago-asked-the-koh-kong-court-to-drop-charge-11032021113546.html
[13] RFA 24-11-2021 https://www.rfa.org/khmer/news/land/four-land-dispute-communities-seek-resolution-from-koh-kong-authority-11242021082140.html
[14] VOD 27 July 2021 https://vodkhmer.news/2021/07/27/oddar-meanchey-provincial-court-orders-more-than-10-residents-intervene/
[15] RFA_3-8-2021: https://www.rfa.org/khmer/news/land/authorities-in-russey-keo-district-dismantle-20-homes-in-boeung-chhouk-a-community-08032021135656.html

រស់នៅទាំងស៊ីអត់ស៊ីឃ្លាន ហ្នឹងហើយខ្ញុំស៊ូងាប់នៅផ្ទះរបស់ខ្ញុំ ខ្ញុំអត់ចេញទៅណាទេ បើគ្មានសំណង ដោះដូរឱ្យខ្ញុំ មិនព្រមចេញទេ...! នេះជាសម្តីប្រជាពលរដ្ឋរងគ្រោះម្នាក់ ។

**ភ្នំពេញ** កាលពីពាក់កណ្តាលខែសីហា ឆ្នាំ២០២១[16] កម្លាំងសមត្ថកិច្ចចម្រុះជិត១០០នាក់ ប្រើគ្រឿងចក្រវាយកម្ទេចផ្ទះពលរដ្ឋ២គ្រួសារ ក្នុងចំណោមពលរដ្ឋដែលរងផលប៉ះពាល់៣៨គ្រួសារនៅភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ហើយនឹងបន្តកម្ទេចផ្ទះប្រជាពលរដ្ឋ៧គ្រួសារទៀត ។ ជម្លោះនេះបានអូសបន្លាយពេលដោយសារគម្រោងអភិវឌ្ឍន៍ផ្តល់សំណងមិនសមរម្យដល់ប្រជាពលរដ្ឋ ។

## ២. ឥទ្ធិពលអ្នកមានអំណាច-មានទ្រព្យ ( ខ្វះការពិគ្រោះយោបល់ជាសាធារណៈនៃគម្រោងអភិវឌ្ឍន៍ )

ពាក្យថា ការអភិវឌ្ឍន៍ ត្រូវបានអ្នកមានទ្រព្យ-មានអំណាចយកមកប្រើប្រាស់ក្នុងគោលបំណងបំពេញនូវមហិច្ឆតាទាញយកប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែជាតុពិត អ្វីដែលយើងបានឃើញនៅពីក្រោយការអភិវឌ្ឍន៍ គឺ ធ្វើឲ្យប្រជាពលរដ្ឋម្ចាស់ដីបាត់បង់ឱកាស បាត់បង់សិទ្ធិទទួលព័ត៌មាន និងសិទ្ធិសំរេចចិត្តនានា បាត់បង់ដីធ្លី-ស្រែចំការ ព្រមទាំងក្លាយជាជនជាប់ចោទ ដោយអ្នកមានទ្រព្យ-មានអំណាចប្តឹងអោយតុលាការចាត់ការបណ្តឹងអាជ្ញាមុន ប្រើកងកំលាំងប្រដាប់អាវុធគម្រាមកំហែង និងរំលោភដីរដ្ឋធ្វើជាកម្មសិទ្ធិ ធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមជាតិ ដូចជាករណី៖

**ខេត្តស្ទឹងត្រែង** មានករណីរំលោភយកដីសហគមន៍ជនជាតិដើមភាគតិចព្នងពីសំណាក់អ្នកមានទ្រព្យ-ក្រុមហ៊ុនអានម៉ារឌី ( និងក្រុមហ៊ុនចិនសីវហ្គេច ) ក្រោមរូបភាពសម្បទានសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍ បានប្រើកម្លាំងប្រដាប់អាវុធដើម្បីធ្វើសកម្មភាពវាស់វែងបោះបង្គោលរំលោភយកដីសមូហភាព ទំហំជាង ៧,០០០ហិកតា របស់ជនជាតិដើមភាគតិចដែលរួមមាន ដីលំនៅដ្ឋាន-ដីចម្ការវិលជុំ-ដីកប់សព-ព្រៃអារក្សអ្នកតា ស្ថិតនៅភូមិក្បាលរមាសចាស់ ឃុំក្បាលរមាស ស្រុកសេសាន[17]។ នៅចុងឆ្នាំ២០២១ ដោយមានការភ័យខ្លាចឥទ្ធិពលអ្នកមានទ្រព្យមាន



អំណាច ក្រោមការសម្របសម្រួលពីអាជ្ញាធរស្រុក ខេត្ត នៅដើមខែវិច្ឆិកា ២០២១ ពួកគាត់បានរៀបចំឯកសារដាក់ទៅសាលាស្រុក-ខេត្ត ដោយប្រជាសហគមន៍ជនជាតិដើមភាគតិចព្នងទាំង៥២គ្រួសារសុខចិត្តលះបង់ជាងពាក់កណ្តាលនៃទំហំដីមានវិវាទ ដោយស្នើសុំយកដីសំរាប់ប្រយោជន៍សមូហភាពសហគមន៍ត្រឹមតែទំហំ ៣,៦៥៦.៩៩ហិកតាប៉ុណ្ណោះ ដែលក្នុងនោះ រួមមានដីស្រែចំការ ដីលំនៅដ្ឋាន ព្រៃអារក្ស ដីកប់សព។ ប៉ុន្តែខាងក្រុមហ៊ុនយល់ព្រមត្រឹមតែ១,១០០ហិកតាប៉ុណ្ណោះ សំរាប់សហគមន៍

[16] RFA_13-8-2021: https://www.rfa.org/khmer/news/land/phnompenh-authorities-demolish-villagers-houses-in-boeng-tumpun-without-compensation-08132021134928.html

[17] VOD 31 March 2021 https://vodkhmer.news/2021/03/31/indigenous-people-stungtreng-accuse-authorities-allowing-companies/

ឬក៏តាមគោលការណ៍សំណង មួយគ្រួសារចំនួន$6,000 សំរាប់ធ្វើផ្ទះ និងដីទំហំ៥ហិកតា ។ តំណាងសហគមន៍បានបញ្ជាក់ថា៖ ពួកគាត់មិនយល់ព្រមទេពីព្រោះបាត់អត្តសញ្ញាណ បាត់បង់កន្លែងជំនឿ និងវប្បធម៌របស់ជនជាតិដើមភាគតិចព្នងនៅសហគមន៍ក្បាលរមាសនេះ។ គាត់បានបន្ថែមថា អាជ្ញាធរស្រុក-ខេត្តប្រាប់ថា បើពួកគាត់ព្រមទទួលយកដីទំហំ១,១០០ហិកតានេះ អាជ្ញាធរនឹងជួយរៀបចំឲ្យពួកគាត់ ។

**ខេត្តបន្ទាយមានជ័យ** ស្រុកព្រះនេតព្រះ ឃុំភ្នំលៀប មានវិវាទដីធ្លី រ៉ាំរ៉ៃអូសបន្លាយពេលច្រើនឆ្នាំដែលគ្មានដំណោះស្រាយច្បាស់លាស់ ធ្វើឲ្យប្រជាពលរដ្ឋអស់ជំនឿថា នឹងទទួលបានយុត្តិធម៌ដោយគេដឹងថា ភាគីជម្លោះជាអ្នកមានអំណាចនៅក្នុងជួររដ្ឋាភិបាល និងប្រជាពលរដ្ឋ១១០គ្រួសារ មានទំហំដី ៤២០ហិកតា...មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងឆ្នាំ២០២១នេះ តុលាការបានកោះហៅតំណាងសកម្មជនដីធ្លី០២នាក់ ដើម្បីធ្វើការសាសួរនៅតុលាការខេត្ត ។

**ខេត្តព្រះសីហនុ** អង្គភាពប្រឆាំងអំពើពុករលួយ និងតុលាការ បានកោះហៅប្រជាពលរដ្ឋដើមបណ្តឹងចំនួន៥៣នាក់ ដើម្បីសាកសួរ បន្ទាប់ពីមានវិវាទដីធ្លីជាមួយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប នៅក្រុងកោះរ៉ុងមានដីទំហំ៣៥ហិកតា ករណីប្រតាយប្រតប់គ្នាដោយហិង្សា និងមានចាប់ប្រជាពលរដ្ឋ ក្នុងព្រឹត្តិការណ៍ការពារាំងតវ៉ាពីសំណាក់ប្រជាពលរដ្ឋម្ចាស់ដំណាំ មិនឲ្យអាជ្ញាធរមានកម្លាំងចម្រុះ ដែលដឹកនាំដោយអភិបាលក្រុងកោះរ៉ុង ប្រើគ្រឿងចក្រឈូសឆាយ បំផ្លាញដំណាំប្រជាពលរដ្ឋមានស្វាយចន្ទី ស្វាយ ខ្នុរជាដើម ក្រោយផុតកំណត់ឱសានុវាទឲ្យប្រជាពលរដ្ឋរុះរើផ្ទះសម្បែងក្នុងរយៈពេល០៣ថ្ងៃជាកំហិត ។

**ខេត្តព្រះសីហនុ** *ជនរងគ្រោះ ក្លាយជាជនជាប់ចោទ ដោយអយុត្តិធម៌ និងត្រូវបានចាប់ឃុំខ្លួនក្នុងពន្ធនាគារ....រីឯចុងចម្លើយដែលជាម្ចាស់ក្រុមហ៊ុនបែរជាមានសេរីភាពជម្មតាទៅវិញ?* រឿងរ៉ាវកើតនៅឃុំបិទត្រាង វិវាទដីធ្លីទំហំ៦០ហិចតា ជាមួយអ្នកមានទ្រព្យ-មានអំណាច បន្ទាប់ពីមានព្រឹត្តិការណ៍ហឹង្សាបាញ់ប្រហារធ្ងន់ធ្ងរលើប្រជាពលរដ្ឋម្ចាស់ដីនៅដើមឆ្នាំ២០១៩ ។ មិនទាន់កន្លងបានប៉ុន្មានខែផង នៅចុងឆ្នាំ២០១៩ កម្លាំងប៉េអឹមបានបន្តបណ្តេញ និងរុះរើលំនៅដ្ឋានចំនួន០២ដងជួនៗគ្នា ព្រមទាំងដកហូតម៉ូតូជិត២០គ្រឿង (ក្រោយមកប្រគល់ឲ្យវិញ) និងចាប់ខ្លួន-ឃុំខ្លួនប្រជាពលរដ្ឋ០៣នាក់ដាក់ពន្ធនាគាររយៈពេល១ឆ្នាំ២ខែ និងសងជាប្រាក់១២លានរៀល ដោយចោទពីបទ " ប្រើអំពើហឹង្សាលើអ្នកកាន់កាប់អចលនវត្ថុ ដោយសុច្ចរិត និងហឹង្សាលើសមត្ថកិច្ច " ។

**ខេត្តកំពង់ស្ពឺ** ប្រជាពលរដ្ឋ មានការស្តោកស្តាយយ៉ាងខ្លាំង ចំពោះភាពអយុត្តិធម៌ ដែលភាគីក្រុមហ៊ុនត្រូវរ៉ូវគ្នាជាមួយអ្នកមានអំណាច ដើម្បីរំលោភយកដីរបស់ពួកគាត់ ហើយថែមទាំងប្តឹងចោទប្រកាន់ពួកគាត់ទាំងបំពានទៀត។ ទំនាស់ដីធ្លីនេះ បានកើតឡើងនៅភូមិពាមទុង ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច តុលាការបានចោទប្រកាន់ និងកោះហៅប្រជាជាជន១៧នាក់ រួមទាំងមេឃុំម្នាក់ និងមេភូមិពីរនាក់ដើម្បីចូលបំភ្លឺ ហើយតុលាការអនុញ្ញាតអោយអ្នកទាំងនោះត្រឡប់មកផ្ទះវិញ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។

**ខេត្តសៀមរាប** ករណីអាជ្ញាធរមូលដ្ឋានគប់គិតជាមួយអ្នកមានទ្រព្យ ប្រើប្រាស់គ្រឿងចក្រឈូស ឆាយដីព្រៃរបស់រដ្ឋជាង១៦ហិចតា ស្ថិតនៅភូមិត្រពាំងឫស្សី ឃុំបឹងមាលា ស្រុកស្វាយលើ ។

ករណីដាច់ដោយឡែកមួយទៀត កើតឡើងនៅភូមិខ្នារ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ជម្លោះដីធ្លីទំហំ៦ហិកតា ជាមួយក្រុមហ៊ុនលីអ៊ុំអេងគ្រុប ។ ក្រុមគ្រួសារជនរងគ្រោះស្នើសុំអន្តរាគមន៍ ពីសាលាឃុំ ប៉ុន្តែពួកគេឆ្លើយថា មិនហ៊ានទេ ព្រោះខ្លាចអំណាចជំទាវមានលុយមានបក្សពួកជាអ្នកជំ ចាំការពារពីក្រោយខ្នង...ផ្ទុយមកវិញ នៅខែមេសា ឆ្នាំ២០២១ បន្ទាប់ពីមានបណ្តឹងពីជំទាវប្រធាន ក្រុមហ៊ុន កម្លាំងសមត្ថកិច្ចស្នងការខេត្ត បានធ្វើការចាប់ខ្លួនជនរងគ្រោះ (ជនជាតិខ្មែរឥស្លាម) ទាំង កំពុងមានជម្ងឺ បញ្ជូនទៅតុលាការ និងឃុំខ្លួនបណ្តោះអាសន្ន ។

**ព្រំប្រទល់ខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំង** ប្រជាពលរដ្ឋជាង៣០០គ្រួសារ ស្ថិតនៅក្នុងភូមិ សាស្រ្ត ភូមិក្បាលដំរី ឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ និងព្រំប្រទល់ស្រុកបរិបូណ៌ ខេត្ត កំពង់ឆ្នាំង ដោយសារភាពយឺតយ៉ាវ ក្នុងការដោះស្រាយវិវាទដីធ្លីទំហំជាង១០០០ហិកតា ដែលបាន ចូលកាន់កាប់ដោយប្រជាពលរដ្ឋក្រីក្រនៅព្រំប្រទល់ខេត្តទាំងពីរ បានបង្ករអោយមានអំពើហឹង្សាការ គម្រាមកំហែង ដោយអាជ្ញាធរមានសមត្ថកិច្ច បានប្រើគ្រឿងចក្រឈូសឆាយ និងបាញ់ថ្នាំសំលាប់ ដំណាំស្រូវបំផ្លាញរោងចាំចំការរបស់ប្រជាពលរដ្ឋអស់ជាង៨ហិកតា ព្រមទាំងធ្វើការព័ទ្ធចាប់ប្រជា ពលរដ្ឋពីរនាក់ យកទៅឃុំខ្លួនបណ្តោះអាសន្នជាងមួយខែ ដោយចោទពីបទ " ញុះញ៉ង់ឲ្យប្រព្រឹត្តបទ ឧក្រិដ្ឋជាអាទិ៍ " ក្រោយពីម្នាក់បានចូលរួមក្នុងការតវ៉ាមិនអោយមានការឈូសឆាយផលដំណាំរបស់ពួក គាត់ និងម្នាក់ទៀតបានថតវិដេអូឡាយ(live) សកម្មភាពអាជ្ញាធរ កំពុងឈូសឆាយ និងបាញ់ថ្នាំសំ លាប់ស្រូវ បំផ្លាញរោងចាំចំការ របស់ប្រជាពលរដ្ឋកាលពីពាក់កណ្តាលឆ្នាំ២០២០ ។ ជម្លោះរ៉ាំរ៉ៃមិន មានដំណោះស្រាយច្បាស់លាស់នេះ បានកក្រើកឡើងវិញជាថ្មីម្តងទៀត[18] នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០២១ ប្រជាពលរដ្ឋជាង៤០០នាក់ បានធ្វើការតវ៉ាបិទផ្លូវជាតិលេខ៥ ដើម្បីទាមទារអោយអាជ្ញាធរ ពន្លឿនដោះស្រាយរឿងដីធ្លីរបស់ពួកគាត់។

**ខេត្តកំពង់ធំ** ករណីរំលោភដោយអ្នកមានទ្រព្យ-មានអំណាចលើផ្ទៃដីចំនួន៥២៨ហិកតា នៅដើមឆ្នាំ ២០២១ តុលាការបានកោះហៅប្រជាពលរដ្ឋចំនួន២៧នាក់ចូលឆ្លើយបំភ្លឺ ហើយតុលាការសំរេចចោទ ប្រកាន់ ប្រជាពលរដ្ឋចំនួន១០នាក់ ពីបទ " ប្រើហឹង្សាលើអ្នកកាន់កាប់អចលនវត្ថុ ដោយសុចរិត " និង បញ្ជូនតំណាងប្រជាពលរដ្ឋ០២នាក់ ទៅឃុំខ្លួននៅពន្ធនាគារខេត្ត បន្ទាប់ពីប្រជាពលរដ្ឋ១៩៦គ្រួសារ បានចូលរួមតវ៉ារាំងមិនអោយគ្រឿងចក្រឈូសឆាយដីព្រៃសហគមន៍ អូរផ្លូវលោក ភូមិដូនឈូក ឃុំនី ពេជ ស្រុកកំពង់ស្វាយ ។ ករណីនេះធ្វើឲ្យប្រជាពលរដ្ឋមានការភ័យខ្លាចការចាប់ខ្លួន-ឃុំខ្លួន នៅពេល ពួកគេដែលលឺថា តុលាការកោះហៅទៅបំភ្លឺរឿងវិវាទដីធ្លីម្តងៗ !

## ៣. ការអនុវត្តច្បាប់មិនពេញលេញ

[18] RFA_19-09-2021: https://www.rfa.org/khmer/news/land/land-protesters-block-national-road-5-for-demanding-authorities-to-resolve-their-land-dispute-09192021195206.html

ការអនុវត្តន៍ច្បាប់ គឺជាអាវុធមុខពីរ ដែលអាចធ្វើឲ្យមានផលវិជ្ជមាន និងក៏អាចបង្កើតឲ្យមានផលអវិជ្ជមាន ប្រសិនបើការអនុវត្តន៍ច្បាប់នោះមានស្តង់ដាពីរផ្សេងគ្នា ដែលធ្វើឲ្យភាពយុត្តិធម៌មានគម្លាតឆ្ងាយគ្នារវាងអ្នកមានអំណាច-មានទ្រព្យ(ឧកញ៉ា) និងប្រជាពលរដ្ឋធម្មតា ជាពិសេសចំពោះវិវាទដីធ្លី ដែលនាំឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម និងប៉ះពាល់ដល់សិទ្ធិពលរដ្ឋ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ប៉ះពាល់ដល់សិទ្ធិភោគៈ និងសិទ្ធិលើកម្មសិទ្ធិ ដូចមានចែងក្នុងច្បាប់ភូមិបាល ការចេញប្លង់កម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ការមិនទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ដោយគ្រាន់តែចេញលិខិតមោឃភាពលើហត្ថលេខារបស់ខ្លួន ក្នុងការទិញលក់ដីធ្លី ការចរចាផ្ដិតមេដៃបង់លុយបញ្ចប់រឿង ការអនុវត្តច្បាប់មានភាពលំអៀងលើអ្នកមានអំណាច-មានទ្រព្យ ដោយតុលាការចាប់ឃុំខ្លួនប្រជាពលរដ្ឋម្ចាស់ដីបង្ខំអោយធ្វើលិខិតសុំទោស ធ្វើកិច្ចសន្យាយល់ព្រមតាមតំលៃក្រុមហ៊ុនបានកំណត់ទុកនិងបញ្ឈប់សកម្មភាព ស្វែងរកយុត្តិធម៌ ដើម្បីជាថ្នូរនឹងការដោះលែងអោយនៅក្រៅឃុំបណ្ដោះអាសន្ន តួយ៉ាង ករណីវិវាទដីធ្លី នៅឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១ និងករណីនៅភូមិត្រពាំងឬស្សី ឃុំបឹងមាលា ស្រុកស្វាយលើខេត្តសៀមរាប វិវាទដីធ្លីទំហំ១៦ហិកតា ជាមួយអ្នកមានទ្រព្យ ដោយកាលពីខែមេសា ឆ្នាំ២០២១ បន្ទាប់ពីមានបណ្ដឹងរបស់លោកជំទាវប្រធានក្រុមហ៊ុន កម្លាំងសមត្ថកិច្ចស្នងការខេត្ត បានធ្វើការចាប់ខ្លួនជនរងគ្រោះ(ជនជាតិខ្មែរឥស្លាម)ទាំងកំពុងមានជម្ងឺ បញ្ជូនទៅតុលាការ និងឃុំខ្លួនបណ្ដោះអាសន្ន ខណៈជនរងគ្រោះស្នើអាជ្ញាធរមូលដ្ឋានអន្តរាគមន៍ជួយដោះស្រាយ តែពួកគេមិនហ៊ានដោយខ្លាចអំណាចអ្នកមានទ្រព្យ។ ប្រសាសន៍សម្ដេចក្រឡាហោម[19] **ស ខេង** ថ្លែងក្នុងពិធីប្រកាសចូលកាន់តំណែងអភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ថា៖ " បញ្ហាប្រឈម បញ្ហាអសកម្មដូចជាទំនាស់ដីធ្លីជាដើម ត្រូវប្រមូលឲ្យអស់យកមកដោះស្រាយប្រកបដោយតម្លាភាព យុត្តិធម៌ "។ បើយើងក្រឡេកមកមើលជំហររបស់ប្រជាពលរដ្ឋ ដែលមានវិវាទដីធ្លីនៅសហគមន៍ហាក់បីដូចជា បញ្ជាក់យ៉ាងច្បាស់ថា[20]ពួកគេមិនមានជំនឿលើប្រព័ន្ធតុលាការក្នុងការដោះស្រាយវិវាទដីធ្លីទៀតទេ ដោយសារកន្លងមកការអូសបន្លាយពេល មិនមានដំណោះស្រាយច្បាស់លាស់ជាច្រើនឆ្នាំមកហើយ ដែលនាំឲ្យពួកគាត់បាត់បង់សិទ្ធិសេរីភាព សិទ្ធិមានលំនៅដ្ឋាន និងប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់នៅប្រចាំថ្ងៃ ។ សហគមន៍រងគ្រោះដីធ្លីបានដាក់ជាប្រធានបទ " ឯណាទៅយុត្តិធម៌សំរាប់អ្នករងគ្រោះដីធ្លី " - តុលាការមិនចាត់ការនូវរាល់ពាក្យបណ្ដឹងដាក់ដោយប្រជាពលរដ្ឋសហគមន៍រងគ្រោះដីធ្លី ខណៈដែលតុលាការចាត់ការយ៉ាងឆាប់រហ័សបណ្ដឹងរបស់ក្រុមហ៊ុន ។

យោងតាមរបាយការណ៍បានបង្ហាញថា៖ ៣៩.០៥% នៃករណីវិវាទដីធ្លីប្រចាំឆ្នាំ២០២១ និង (៥១.០៩%ឆ្នាំ២០២០) គឺជាវិវាទដីធ្លីកើតឡើងរវាងភាគីអ្នកមានអំណាច-មានទ្រព្យ(ឧកញ៉ា)-ក្រុមហ៊ុន ជាមួយនឹងប្រជាពលរដ្ឋធម្មតា (ប្រជាសហគមន៍) ។ ហើយឆ្លងតាមការអង្កេតឃើញថា ភាគច្រើននៃដំណោះស្រាយមានភាពយឺតយ៉ាវ មិនច្បាស់លាស់ និងមានភាពលំអៀង តាំងពីថ្នាក់មូលដ្ឋាន

---

[19] VOD_04 October 2021: https://www.vodkhmer.news/2021/10/04/sar-kheng-says-land-dispute-will-affect-the-vote-if-not-solved/?fbclid=IwAR2wL1vLN0f_dGqh3i07bIaYCRsf9nLsHlLdnokitc04-hsg-AiNVEV25cg

[20] RFA Khmer 8-12-2021: សន្និសីទសហគមន៍ថ្នាក់ជាតិធ្វើតាមសណ្ដាញសង្គមវិដេអូហ្សូមនៅថ្ងៃទី៨ខែធ្នូឆ្នាំ២០២១មានបណ្ដាញសហគមន៍ចូលរួម១០០០ នាក់ https://streamer1.rfaweb.org/stream/KHM/KHM-2021-1208-1230.mp3

ហេតុដល់ថ្នាក់ជាតិ ជាពិសេសប្រព័ន្ធតុលាការប្រើធន្ធានុសិទ្ធិសំរេចក្តីប្រកបដោយអគតិទាំង៤ចាត់ការបណ្ដឹងអាជ្ញាមុន   និងឆាប់រហ័ស បន្ទាប់ពីមានបណ្ដឹងពីក្រុមហ៊ុន ឬអ្នកមានទ្រព្យ-មានអំណាចដោយចេញដីកាកោះហៅឲ្យចូលបំភ្លឺ និងចាប់ឃុំខ្លួនបណ្តោះអាសន្ន...។ល។

តើបរិបទសង្គមកម្ពុជាបច្ចុប្បន្នមានការអនុវត្តន៍ច្បាប់មិនពេញលេញ មានភាពលំអៀងនិងគ្មានតម្លាភាពមែនឬ  ?  ប្រសិនបើយើងក្រឡេកមកមើលករណី ការមិនទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន មេឃុំមួយចំនួន បានចេញលិខិតមោឃភាពលើហត្ថលេខារបស់ខ្លួន ពាក់ព័ន្ធដីធ្លីក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវចម្រុះក្រោយមានការណែនាំពីក្រសួងបរិស្ថាន តាមលិខិតលេខ៦០៥ ស.ណ.ប.ស្ក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ស្តីពីសំណើសុំអន្តរាគមន៍ចាត់វិធានការឲ្យបញ្ឈប់ជាបន្ទាន់ និងមោឃភាព នូវរាល់ការចុះហត្ថលេខា  ឬការបញ្ជាក់ទទួលស្គាល់លើលិខិតផ្ទេរសិទ្ធិពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលិខិតទិញលក់ដីធ្លីរដ្ឋ និងការបញ្ជាក់លើប្លង់បង្ហាញទីតាំងជាអាទិ៍ដែលធ្វើឡើង  នៅលើដីក្នុងតំបន់ការពារធម្មជាតិ  និងក្នុងរបៀងអភិរក្សជីវៈចម្រុះ  ។ តើមេឃុំ-ចៅសង្កាត់ដែលនិយាយដោះសារថា  ខ្លួនមិនយល់ច្បាប់ មិនចេះច្បាប់  អាចជាតំណាងប្រជាពលរដ្ឋមូលដ្ឋានបានល្អដែរឬទេ? តើការនិយាយដោះសាររបស់មេឃុំ-ចៅសង្កាត់  អាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរឬទេ? តើមេឃុំ-ចៅសង្កាត់ដែលមិនទទួលខុសត្រូវអាចដឹកនាំមូលដ្ឋានប្រកបដោយវឌ្ឍនភាព និងស្ថិរភាពដែរឬទេ  ? តើទង្វើមិនទទួលខុសត្រូវរបស់មេឃុំ-ចៅសង្កាត់មួយចំនួននេះអាច ប៉ះពាល់ដល់សមត្ថភាពដឹកនាំមូលដ្ឋាន របស់មេឃុំ-ចៅសង្កាត់ទាំង១,៦៥៧២ ទូទាំងប្រទេសដែឬទេ ? តើក្រសួងមហាផ្ទៃមានចំណែកក្នុងការទទួលខុសត្រូវលើការប្រព្រឹត្តខុសរបស់មេឃុំ-ចៅសង្កាត់ដែឬទេ ?  ដូចជាមេឃុំ-ចៅសង្កាត់មួយចំនួននៅក្នុងខេត្តៈ



**ខេត្តកំពង់ស្ពឺ** ស្រុកភ្នំស្រួច មេឃុំត្រែងត្រយឹង[21]៖ កាលពីថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២១ បានប្រកាសធ្វើមោឃភាពការចុះហត្ថលេខារបស់លោកស្រីកន្លងមកទាំងអស់  ដែលពាក់ព័ន្ធឯកសារលិខិតស្នើសុំសិទ្ធិកាន់កាប់ដីធ្លីលិខិតស្នើសុំប្រើប្រាស់ដីធ្លី  លិខិតទិញលក់ជាដើម ដោយសំអាងថា ការចុះហត្ថលេខាកន្លងមក  គឺដោយសារលោកស្រី  ពុំសូវយល់ដឹងពីច្បាប់ទម្លាប់ច្រើន ដោយឃើញពួកគេអាស្រ័យផលជាក់ស្តែង ។ ជាមួយគ្នានេះ នៅស្រុកឱរ៉ាល់រដ្ឋបាលឃុំត្រពាំងជោ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១  ក៏បានចេញលិខិតបដិសេធ  និងនិរាករណ៍ការកាន់កាប់ដីមានទំហំជាង២០០០ហិកតា  ដែលស្ថិតក្នុងភូមិក្បាលដំរី និងភូមិក្រវៀក របស់បុគ្គលម្នាក់ ។



[21] Phnom Penh Post_6-7-2021: https://www.postkhmer.com/national/2021-07-06-1027-219344.html

**ខេត្តកំពង់ធំ** ស្រុកសន្ទុក មេឃុំកកោះ[22] កាលពីចុងខែឧសភា ឆ្នាំ២០២១បានចេញលិខិតបដិសេធដោយមោឃភាព និងនិរាករណ៍លិខិតដែលបានចុះហត្ថលេខា នាពេលកន្លងមកដោយក្នុងនោះមានលិខិតលក់ ទិញ និងលិខិតផ្ទេរសិទ្ធិកាន់កាប់គ្រប់ប្រភេទ ដែលមិនទាន់ចុះបញ្ជីមានការទទួលស្គាល់ដោយ រដ្ឋបាលសុរិយោដី ជាពិសេសនៅក្នុងភូមិសាស្ត្រដីសហគមន៍គ្រប់ញក ដែលស្ថិតក្នុងភូមិសាលាសន្ទុក និងភូមិជីមាយ។


តែម ធន មេភូមិកកោះ ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ និងលិខិតរបស់លោក។ រូបថត ហ្វេសប៊ុក

**ខេត្តកំពត** ស្រុកទឹកឈូ មេឃុំចំនួនបីគឺ[23]៖ ឃុំព្រែកត្នោត ឃុំកោះតូច ឃុំបឹងទូក កាលពីចុងខែកក្កដា ឆ្នាំ២០២១ បានចេញលិខិតបដិសេធដោយធ្វើការមោឃភាពលើការចុះហត្ថលេខា លើឯកសារលិខិតស្នើសុំសិទ្ធិកាន់កាប់ដីធ្លី លិខិតស្នើសុំប្រើប្រាស់ដីធ្លី លិខិតទិញលក់ ប្លង់បង្ហាញទីតាំងគ្រប់ប្រភេទស្ថិតនៅក្នុងតំបន់កាន់កាប់ធនធានធម្មជាតិ និងក្នុងរបៀងអភិរក្សជីវចម្រុះ នៃតំបន់ឧទ្យានជាតិមុនីវង្សបូកគោ ។ បញ្ហានេះកើតឡើង ក្រោយពីមានជម្លោះដីធ្លីនៅជុំវិញតំបន់ឧទ្យានជាតិមុនីវង្សបូកគោ បានកើតឡើងជាយូមកហើយ ដោយប្រជាពលរដ្ឋបានដាក់សំណើរទៅអាជ្ញាធរខេត្ត ដើម្បីជួយដោះស្រាយ ។



**ខេត្តកោះកុង** កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១[24] រដ្ឋបាលខេត្តកោះកុង បានជូនដំណឹង អំពីមោឃភាពរាល់ការទិញលក់ដីនៅតំបន់ការពារធម្មជាតិ តំបន់សហគមន៍ និងក្នុងតំបន់គម្របព្រៃឈើនៅភូមិសាស្ត្រ ក្នុងភូមិ-ឃុំមួយចំនួន ជាពិសេសនៅក្នុងស្រុកបូទុមសាគរ ស្រុកកោះកុង ស្រុកគីរីសាគរ ស្រុកថ្មបាំង ។

**ខេត្តមណ្ឌលគីរី** ដូចគ្នានេះ មានមេឃុំ-ចៅសង្កាត់មួយចំនួនទៀត ក៏បានចេញលិខិតបដិសេធជាបន្តបន្ទាប់ ដើម្បីមោឃភាពហត្ថលេខារបស់ខ្លួនកន្លងមក ពាក់ព័ន្ធនឹងលិខិតស្នើសុំសិទ្ធិកាន់កាប់ដីធ្លីលិខិតស្នើសុំប្រើប្រាស់ដីធ្លី លិខិតទិញលក់ ដែលពួកគេបានផ្តល់សំអាងលើលិខិតនានា ជុំវិញការកាន់កាប់អចលនទ្រព្យ នៅតំបន់ការពារ និងតំបន់អភិរក្សនេះ ។

## IV. ក្របខណ្ឌគតិយុត្តិ

### ✍ ច្បាប់ជាតិ៖

[22] Phnom Penh Post_6-7-2021: https://www.postkhmer.com/national/2021-07-06-1027-219344.html

[23] FK News Media_25-7-2021: https://www.facebook.com/watch/?v=556731625486341 & and Phnom Penh Post on 27-7-2021: https://www.postkhmer.com/national/2021-07-27-1055-220511.html

[24] នគរវត្ត 14-7-2021: http://nokorwatnews.com/archives/564913

**រដ្ឋធម្មនុញ្ញ** ព្រះរាជាណាចក្រកម្ពុជាជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ -មាត្រា៣៨ បានរ៉ាប់រង មិនឲ្យមានការរំលោភបំពានលើរូបរាង្គកាយបុគ្គលណាមួយឡើយ...{}...ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់........ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាង្គកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឲ្យធ្វើឡើយ ។ និងមាត្រា៤៤ បានចែងថា ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ...{}...កម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតនៅក្រោមការគាំពារនៃច្បាប់...{}...ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវអោយធ្វើការក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

**ច្បាប់ភូមិបាល២០០១៖** មាត្រា៥ គ្មានបុគ្គលណាមួយត្រូវបានដកហូតកម្មសិទ្ធិរបស់ខ្លួន ប្រសិនបើការដកហូតនោះមិនមែន ដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។ ហើយមាត្រា៣៦ បើវិធានការបណ្តេញចេញ បង្កាប់ដោយតុលាការអាចបណ្តាលអោយមានភាពវឹកវរ ឬមានផលវិបាកធ្ងន់ធ្ងរដល់សង្គម អាជ្ញាធរមានសមត្ថកិច្ចអាចសុំព្យួរការអនុវត្តន៍ជាបណ្តោះអាសន្នបាន ។ និងមាត្រា២៥៣ ជនណាដែលប្រព្រឹត្តអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែ ដល់២ឆ្នាំ និងពិន័យជាប្រាក់ ដោយពុំទាន់គិតបញ្ចូលនូវទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្សជាតិ ។ ចំណែកមាត្រា២៦១បានចែងពី មន្ត្រី ឬអាជ្ញាធរ ដែលបានប្រើអំណាចដោយរំលោភ ទោះមានបញ្ជាក្តី ឬគ្មានបញ្ជាក្តីដើម្បីដកហូតអចលនវត្ថុពីអ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ និងទោសរដ្ឋបាលថែមទៀត...បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សា ចារី-អ្នកផ្តើមគំនិតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែ ដល់២ឆ្នាំ។

**ក្រមព្រហ្មទណ្ឌ៖** ជារឿយៗ ញឹកញាប់បំផុត ដែលតុលាការនៅក្នុងប្រទេសកម្ពុជានិយមប្រើប្រាស់មាត្រាមួយចំនួន ដើម្បីធ្វើការចោទប្រកាន់-ចាប់ខ្លួន-ឃុំខ្លួនសកម្មជន ក៏ដូចជាប្រជាពលរដ្ឋក្នុងវិវាទដីធ្លីក្នុងគោលបំណងពន្លឿននីតិវិធីលើបណ្តឹងអាជ្ញាជាមុនដូចជា: មាត្រា២១៨ បទហិង្សាមានស្ថានទម្ងន់ទោស - មាត្រា២៣១ បទគំរាមកំហែង - មាត្រា៤១១ បទធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស - មាត្រា៤៩៥ បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ - មាត្រា៥០៤ បទប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស។

**ក្រមនីតិវិធីព្រហ្មទណ្ឌ** បញ្ហាចំបង ហើយក៏ជាឫសគល់នៃបញ្ហាដែលកំពុងតែលាក់ខ្លួននៅពីក្រោយវាំងននយុត្តិធម៌ គឺការគម្រាមកំហែង-បំបាក់ស្មារតីគូភាគីម្ខាងទៀតដែលជាប្រជាពលរដ្ឋ តំណាងសហគមន៍ដីធ្លី ដើម្បីតម្រូវចិត្ត ឬខ្លាចឥទ្ធិពល អ្នកមានទ្រព្យ-មានអំណាច សវនាការដោះស្រាយវិវាទដីធ្លីតុលាការតែងតែប្រើអាទិភាពពន្លឿននីតិវិធីបណ្តឹងអាជ្ញាជាមុន ដោយប្រើ៖ មាត្រា២០៥ មូលហេតុនៃ

ការឃុំខ្លួនបណ្ដោះអាសន្ន - មាត្រា២១៧ ការដោះលែងឲ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ " ជារឿយៗ....ក្រោយពីជនត្រូវចោទធ្វើការសុំទោស-សារភាពកំហុស និងធ្វើកិច្ចសន្យាយល់ព្រមបញ្ឈប់សកម្មភាពតវ៉ា " - និងមាត្រា២២៣ កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ " ក្រោយពីតុលាការសម្រេចឲ្យនៅក្រៅឃុំ " ។

**ច្បាប់ស្ដីពីការគ្រប់គ្រងឃុំ-សង្កាត់** មាត្រា៤៣ តួនាទីភារកិច្ចបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ-សង្កាត់ -មាត្រា៨៤ ការទទួលពិន័យ និងទោសទណ្ឌ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ដែលមិនគោរពតាមបទបញ្ញត្តិច្បាប់ ។ ឧទាហរណ៍ដូចជាករណីមេឃុំ-ចៅសង្កាត់ចេញលិខិតមោឃភាពហត្ថលេខា និងប្រថាប់ត្រាពាក់ព័ន្ធដីធ្លី និងធនធានធម្មជាតិ ។

## ៚ ច្បាប់អន្តរជាតិ និងយន្តការសិទ្ធិមនុស្ស៖

**សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស៖** មាត្រា៩ គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន-ឃុំខ្លួនឬនិរទេសខ្លួនដោយបំពានឡើយ ។ និងមាត្រា១៧ មនុស្សគ្រប់រូបទោះជាបុគ្គលក្ដី សមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ...គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ ។

តាមទិដ្ឋភាពសិទ្ធិមនុស្ស ដីធ្លីអាចជះឥទ្ធិពលដល់បញ្ហាដូចជា៖ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ ការកសាងសន្តិភាព ផែនការអភិវឌ្ឍន៍ជនបទ ដែលអង្គការសហប្រជាជាតិបានផ្ដល់នូវអនុសាសន៍ពាក់ព័ន្ធនឹងការព្រួយបារម្ភណ៍៖

**របាយការណ៍អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**[25] A/HRC/48/49 ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២១ ចំនុចទី៤៤ បានកត់សំគាល់ថា ស្ថានភាពដីធ្លីនៅប្រទេសកម្ពុជាកំពុងមានបញ្ហាយ៉ាងខ្លាំង សហគមន៍ក្រីក្រ ងាយរងគ្រោះ កំពុងតែបន្តប្រឈមនឹងការបណ្ដេញចេញដោយបង្ខំ ដែលបណ្ដាលមកពីការផ្ដល់ដីសម្បទាន ឲ្យបុគ្គលមានទំនាក់ទំនងល្អជាមួយគណបក្សកាន់អំណាច ។ នៅចំនុនចទី៦៦(អូ) នៃរបាយការណ៍បានផ្ដល់អនុសាសន៍រដ្ឋាភិបាល៖ អនុម័តសេចក្ដីព្រាងគោលការណ៍ណែនាំជាតិស្ដីពីការបណ្ដេញចេញ និងការផ្លាស់ប្ដូរទីលំនៅដែលស្របតាមគោលការណ៍គ្រឹះ និងគោលការណ៍ណែនាំស្ដីពីការបណ្ដេញចេញ និងការផ្លាស់ទីលំនៅ ផ្អែកលើការអភិវឌ្ឍន៍។

**របាយការណ៍អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិប្រចាំកម្ពុជា**[26] A/HRC/48/79 ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២១ ចំនុចទី៦៥ បានកត់សំគាល់ថា ការប្រកួតប្រជែងដណ្ដើមដីធ្លី និងធនធាននៅក្នុងសេដ្ឋកិច្ចកំពុងលូតលាស់ គឺជាការប្រកួតប្រជែងមួយ ក្នុងចំណោមការប្រកួតប្រជែងបំផុតដែលអាចមើលឃើញពីចំណុចវិវាទ និងបង្កបញ្ហាប្រឈមដល់ការអភិរក្សព្រៃឈើ និងធនធានធម្មជាតិក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រួមទាំងការបណ្ដេញចេញ និងផ្លាស់ទីលំនៅរបស់ប្រជាសហគមន៍។

---

[25] https://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session48/Documents/A_HRC_48_49.docx
[26] 1st Report Special Rapporteur-A/HRC/48/79_on 03 August 2021: https://undocs.org/A/HRC/48/79

**យន្តការពិនិត្យជាសកលតាមកាលកំណត់**(UPR)[27] ជុំទី៣ប្រព្រឹត្តទៅក្នុងឆ្នាំ២០១៩អនុសាសន៍លេខ១១០.២៣ រដ្ឋាភិបាលបានទទួលយកអនុសាសន៍**ប្រទេសអូស្ត្រាលី៖** ធានាថា រាល់វិវាទដីធ្លីដែលមិនទាន់សម្រេចការបណ្តេញចេញ និងផ្លាស់ទីលំនៅ ត្រូវបានដោះស្រាយដោយយុត្តិធម៌តម្លាភាពដោយបានចរចារ និងផ្តល់សំណងសមរម្យ ។ និងអនុសាសន៍លេខ១១០.៨៥ **ប្រទេសអៀកឡង់៖** ចាត់វិធានការទាំងអស់ដើម្បីការពារ និងគាំទ្រ អ្នកសារព័ត៌មាន-អ្នកការពារសិទ្ធិមនុស្ស-កម្មករសហជិព-សកម្មជនដីធ្លី និងបរិស្ថាន និងសកម្មជនសង្គមស៊ីវិលដទៃទៀត និងសមាជិកនយោបាយប្រឆាំង ។

**គណកម្មាធិការសិទ្ធិមនុស្ស**(HRC)[28] អនុសាសន៍ឆ្នាំ២០១៩ ចំនុចទី៤៧ បានបញ្ជាក់ពីកង្វល់អំពីការរឹតត្បិតហួសហេតុ សេរីភាពការជួបជុំដោយសន្តិវិធី និងការប្រជុំជាសាធារណៈ រួមទាំងសិទ្ធិមនុស្សចំពោះការចោទប្រកាន់ពីការប្រើកម្លាំងមិនសមាមាត្រ និងការចាប់ខ្លួនដោយបំពាន របស់មន្ត្រីអនុវត្តច្បាប់ដើម្បីរារាំងបង្អាក់សកម្មភាពតវ៉ាទាក់ទងនឹងការដេកហូតដីធ្លី។

**គណកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី**(CEDAW)[29] ចំនុច៤៦(ខ) ផ្តល់អនុសាសន៍ដល់រដ្ឋភាគី ធានាថាគោលនយោបាយគម្រោង និងការអនុវត្តពាក់ព័ន្ធ នឹងការអភិវឌ្ឍន៍ និងអភិបាលកិច្ចដីធ្លី រួមទាំងគោលនយោបាយដែលអាចផ្លាស់ប្តូទីលំនៅ ត្រូវស្របតាមស្តង់ដារអន្តរជាតិពាក់ព័ន្ធរួមទាំងគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍន៍ ការបណ្តេញចេញ និងការផ្លាស់ទីលំនៅ ហើយជនរងគ្រោះនៃការបណ្តេញចេញ និងការផ្លាស់ទីលំនៅដោយបង្ខំ ត្រូវបានផ្តល់ជូននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពរួមទាំងសំណងទាន់ពេលវេលា។

**គណកម្មាធិការប្រឆាំងទារុណកម្ម**(CAT)[30] ចំនុចទី៣៨ បានផ្តល់អនុសាសន៍ពាក់ព័ន្ធការព្រួយបារម្ភណ៍របស់ខ្លួនចំពោះរបាយការណ៍ នៃការកើនឡើងលើការវាយប្រហារអ្នកការពារសិទ្ធិមនុស្សការគំរាមកំហែង រួមទាំងការឃុំខ្លួនតាមអំពើចិត្ត ការឃុំខ្លួនបណ្តោះអាសន្នយូរក្នុងវិវាទដីធ្លីជាញឹកញាប់លើដីកសិកម្ម។

**គណកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌**(CESCR)[31] បានផ្តល់អនុសាសន៍សម្តែងការព្រួយបារម្ភចំពោះរបាយការណ៍នៃការបាត់ខ្លួនដោយបង្ខំ និងការសម្លាប់សកម្មជនដីធ្លី និងសកម្មជនបរិស្ថាន ហើយជនល្មើសជាញឹកញាប់មិនត្រូវបានផ្តន្ទាទោសនោះទេ ។

## V. **យន្តការដោះស្រាយវិវាទ**

---

[27] UPR 32th 2019_List of recommendation made to Cambodia its responses (EN): https://www.upr-info.org/en/review/Cambodia
[28] CCPR/C/VNM/CO/3 (CCPR 2019 ): https://uhri.ohchr.org/en/search-human-rights-recommendations
[29] CEDAW/C/PHL/CO/7-8 (CEDAW 2016 ): https://uhri.ohchr.org/en/search-human-rights-recommendations
[30] CAT/C/GTM/CO/7 (CAT 2018 ): https://uhri.ohchr.org/en/search-human-rights-recommendations
[31] E/C.12/THA/CO/1 (CESCR 2015 ): https://uhri.ohchr.org/en/search-human-rights-recommendations

ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៤៧ បានកំណត់អំពីនីតិវិធីដោះស្រាយវិវាទដីធ្លី រវាងភាគីចំពោះអចលនវត្ថុ...។ យោងតាមសេចក្តីប្រកាសព័ត៌មានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ បានប្រកាសអំពីយន្តការទាំងបួន ដើម្បីដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋរួមមាន៖ (១)គណៈកម្មការសុរិយោដី (២)អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (៣)យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ(៤)យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ សេចក្តីប្រកាសដដែលបានបង្ហាញពីការដោះស្រាយវិវាទដីធ្លី បើគិតត្រឹមបំណាច់ខែមេសា ឆ្នាំ២០១៩ ក្រសួងបានទទួលពាក្យបណ្តឹងចំនួន១០,០៧៨ករណី ដោះស្រាយបញ្ចប់រឿង៨,០៦២ករណី និងកំពុងបន្តដោះស្រាយ២,០១៦ករណី បើប្រៀបនឹងលទ្ធផលដោះស្រាយវិវាទក្នុងឆ្នាំ២០២០[32] ក្រសួងទទួលបានពាក្យបណ្តឹងចំនួន៥៦៦ករណី ដោះស្រាយបញ្ចប់ជាស្ថាពរចំនួន៥១ករណី-ធ្វើលិខិតឆ្លើយតបទៅម្ចាស់បណ្តឹង និងបង្វែររឿងទៅសមត្ថកិច្ចពាក់ព័ន្ធចំនួន១៦ករណី ។

**ក្រុមប្រឹក្សាឃុំ-សង្កាត់**[33] ករណីមានទំនាស់កើតឡើងក្នុងសហគមន៍ ដំបូងយើងអាចដាក់បណ្តឹងទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលមានតួនាទីជាអ្នកសម្រុះសម្រួល នៅថ្នាក់មូលដ្ឋានមុនពេលករណីនោះអាចត្រូវបញ្ជូនបន្តទៅថ្នាក់លើ ប្រសិនបើមិនមានកិច្ចព្រមព្រៀង ។

**គណៈកម្មការសុរិយោដី** មានបេសកកម្មដោះស្រាយវិវាទអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី ។ គណកម្មការនេះបែងចែងថ្នាក់ស្រុក-ខណ្ឌ ថ្នាក់ខេត្ត-ក្រុង ថ្នាក់ជាតិ ។ យោងតាមរបាយការណ៍លទ្ធផលដោះស្រាយវិវាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ២០២០[34] បានបង្ហាញថា ចាប់ពីឆ្នាំ២០០៣ ដល់ដំណាច់ឆ្នាំ២០២០ គណៈកម្មការសុរិយោដីក្រុង-ស្រុក-ខណ្ឌ ទទួលបានពាក្យបណ្តឹងចំនួន ៨,៩៦១ករណី ដោះស្រាយបញ្ចប់ជាស្ថាពរចំនួន ៤,២៨៩ករណី ច្រានចោលដោយខុសសមត្ថកិច្ចចំនួន២,៩៦៩ករណី ភាគីស្នើសុំដកពាក្យបណ្តឹងចំនួន ៩៥១ករណី និងកំពុងបន្តដោះស្រាយចំនួន៧៥២ករណី បើធៀបឆ្នាំ២០២០ គណៈកម្មការទទួលបានពាក្យបណ្តឹងចំនួន២៦១ករណី បានដោះស្រាយបញ្ចប់ជាស្ថាពរចំនួន១២៥ករណី ច្រានចោលដោយខុសសមត្ថកិច្ចចំនួន ១២២ករណី ភាគីស្នើសុំដកពាក្យបណ្តឹងចំនួន ៣៣ករណី ។

**គណៈកម្មការរដ្ឋបាល** មានភារៈកិច្ចផ្សះផ្សារវិវាទដីមិនទាន់មានប័ណ្ណកម្មសិទ្ធិ ក្នុងអំឡុងពេលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ករណីមិនសះជាត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** ជាយន្តការថ្នាក់ជាតិ បំពេញបន្ថែមគណៈកម្មាការសុរិយោដី ។ អាជ្ញាធរនេះ មានភារៈកិច្ចត្រួតពិនិត្យទំនាស់ដីធ្លីនានា ដែលផុតពីភារៈកិច្ចរបស់គណៈកម្មាការសុរិយោដី ។ យោងតាមរបាយការណ៍លទ្ធផលដោះស្រាយវិវាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម

---

[32] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ http://www.mlmupc.gov.kh/?page=document&menu1=214&menu2=292&ref_id=24&ctype=article&id=292&lg=kh

[33] អនុក្រិត្យលេខ២២ អ.ន.ក្រ.បក ចុះថ្ងៃទី២៥ ខែមិន ឆ្នាំ២០០២ មាត្រា៦១ តួនាទីឃុំ-សង្កាត់

[34] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១: http://www.mlmupc.gov.kh/?page=document&menu1=214&menu2=292&ref_id=24&ctype=article&id=292&lg=kh

និងសំណង់ឆ្នាំ២០២០ ចាប់ពីដំបូងរហូតមកដល់បំណាច់ឆ្នាំ២០២០ អាជ្ញាធរបានទទួលពាក្យបណ្តឹង ចំនួន១,៩៤៣ករណី ដោះស្រាយបានចំនួន១,៧៩៩ករណី និងកំពុងដោះស្រាយចំនួន១៤៤ករណី បើធៀបឆ្នាំ២០២០ មានបណ្តឹងចំនួន៤៥ករណី ដោះស្រាយបញ្ចប់ស្ថាពរចំនួន២៨ករណី បង្វែរទៅម្ចាស់បណ្តឹង២ករណី និងប្រានចោលចំនួន១ករណី ។

**យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ** មានសមត្ថកិច្ចដោះស្រាយទំនាស់ដីធ្លីទាំងឡាយណាដែលភាគីមិនយល់ព្រមសេចក្តីសម្រេចគណៈកម្មាការសុរិយោដី រួមទាំងដីបានចុះបញ្ជី និងដីមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ។

## VI. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជម្លោះដីធ្លីនៅប្រទេសកម្ពុជា កាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំគិតជាមធ្យមក្នុងមួយខែក្រសួងទទួលបណ្តឹងជាផ្លូវការចំនួន៤៧ករណី ដោះស្រាយបានតែ៤ករណី (ស្មើ៩%) បើយោងតាមរបាយការណ៍ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឆ្នាំ២០២០។ ដូច្នេះក្នុងចំណោមបណ្តឹងដែលកកស្ទះមិនទាន់ដោះស្រាយ៩១% ភាគច្រើនជាបណ្តឹងមានវិវាទរវាងប្រជាពលរដ្ឋសហគមន៍ ជាមួយនឹងក្រុមហ៊ុន អ្នកមានទ្រព្យ អ្នកមានអំណាច ឬអ្នកស្និទ្ធនឹងអ្នកមានអំណាច បានរំលោភយកដោយផ្តល់សំណងតម្លៃទាបបំផុត ក្រោមលេសការអភិវឌ្ឍន៍ ។ លើសពីនេះទៀត ដើម្បីគម្រាមកំហែងបំបាក់ស្មារតីប្រជាពលរដ្ឋសហគមន៍ មិនឲ្យមានការតវ៉ាទាមទារសិទ្ធិសម្រេចចិត្ត ក្នុងការចាត់ចែងដីធ្លីពួកគាត់ត្រូវបានរារាំងដោយកងកម្លាំងប្រដាប់អាវុធការពារអោយក្រុមហ៊ុន ព្រមទាំងប្រើអំពើហិង្សារហូតដល់បាញ់បោះ ដាក់ខ្នោះឃ្នាង ចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួន ។ ម្យ៉ាងវិញទៀត បើទោះបីដឹងថា វិវាទដីធ្លី គឺជាករណីរដ្ឋប្បវេណីក៏ដោយ ដើម្បីតែតម្រូវចិត្តពួកអ្នកមានទ្រព្យ ឬមានអំណាចមួយចំនួននោះ តុលាការព្យាយាមពន្លឿននីតិវិធីបណ្តឹងអាជ្ញាជាមុន ដើម្បីចោទប្រកាន់ ឃុំខ្លួនទៅលើភាគីប្រជាសហគមន៍ទាំងមិនទាន់ដឹងថា អ្នកណាជាម្ចាស់កម្មសិទ្ធិពិតប្រាកដផង ដូចជាករណីវិវាទដីធ្លីកើតឡើងនៅៈ ខេត្តកណ្តាល ករណីស្រុកកណ្តាលស្ទឹង ជាមួយក្រុមហ៊ុនអូស៊ីអាយស៊ីសាងសង់ព្រលានយន្តហោះ ករណីស្រុកស្អាង ការស្លាប់សកម្មជនដីធ្លី បន្ទាប់ពីបញ្ជូនដល់មន្ទីរពេទ្យបង្អែកតាខ្មៅ ករណីស្រុកកៀនស្វាយ ការចាប់ឃុំខ្លួនសកម្មជនដីធ្លី ករណីស្រុកអង្គស្នួល ការបាញ់ប្រជាពលរដ្ឋរបួសស្មារធ្ងន់ធ្ងរ ពេលតវ៉ារឿងវិវាទដីធ្លី និងខេត្តត្បូងឃ្មុំ ការគម្រាមកំហែង បាញ់រះប្រើដំបងធក់មកលើស្ត្រីកូនខ្ចី ចាប់ឃុំខ្លួនសកម្មជនដីធ្លីដាក់ពន្ធនាគារច្រើននាក់ជាដើម...។ល។

សកម្មភាពទាំងនេះ បាននឹងកំពុងដើរផ្ទុយទៅនឹងគោលការណ៍ច្បាប់ ទាំងច្បាប់ជាតិ ច្បាប់អន្តរជាតិ ក៏ដូចជា យន្តការសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងអនុសាសន៍របស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងវិវាទដីធ្លីមួយចំនួនផងដែរ ។ ដូច្នេះ ដើម្បីចូលរួមក្នុងការដោះស្រាយបញ្ហាខាងលើ សមាគមអាដហុកមានអនុសាសន៍មួយចំនួន សំរាប់ជាមូលដ្ឋានក្នុងការពិចារណាដូចខាងក្រោមៈ

1. តុលាការគប្បីប្រើប្រាស់យន្តការបង្អង់បណ្តឹងអាជ្ញាៈ បញ្ឈប់ការចាប់ខ្លួន-ចោទប្រកាន់-ឃុំខ្លួនគូភាគីក្នុងរឿងវិវាទដីធ្លី ។ ផ្ទុយទៅវិញ ត្រូវដាក់ទោសទណ្ឌចំពោះបុគ្គល ឬភាគីណាដែលបានប្រើហិង្សាទៅរំលោភបំពាន បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ផ្ទះសម្បែង ផលដំណាំរបស់ភាគីម្ខាងទៀតដោយខុសច្បាប់ ។
2. ចៅក្រមត្រូវប្រើការឃុំខ្លួនបណ្តោះអាសន្ន ជាជម្រើសចុងក្រោយបំផុត នៅក្នុងដំណើរការនីតិវិធី(មាត្រា២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ) ពិសេសករណីជម្លោះដីធ្លី ។
3. អនុម័តសេចក្តីព្រាងគោលការណ៍ណែនាំជាតិ និងក្របខណ្ឌគតិយុត្ត ការប្រើប្រាស់កម្លាំងប្រដាប់អាវុធ ការបង្ក្រាបរារាំង សកម្មភាពប្រឆាំងតវ៉ាការបណ្តេញចេញ ការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋក្នុងរឿងវិវាទដីធ្លី ។
4. បញ្ឈប់ការប្រើកងកម្លាំងប្រដាប់អាវុធទៅបង្ក្រាបអ្នកតវ៉ាទាមទារដោយសន្តិវិធី ដើម្បីការពារភាគីក្រុមហ៊ុន និងបុគ្គលមានទ្រព្យ-មានអំណាច ។
5. ពិនិត្យការអនុវត្តន៍ អនុសាសន៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងបញ្ហាវិវាទដីធ្លីប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។
6. ក្រសួងពាក់ព័ន្ធ តុលាការ គណៈកម្មការដោះស្រាយវិវាទដីធ្លីពន្លឿន និងពង្រឹងការដោះស្រាយបញ្ចប់វិវាទដីធ្លីដែលនៅកកស្ទះឲ្យបានឆាប់រហ័ស មានតម្លាភាព យុត្តិធម៌ និងមិនលំអៀង ។
7. ពង្រឹង និងពិនិត្យវាយតំលៃលើសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីពាក់ព័ន្ធ និងផ្តល់សិទ្ធិអំណាចដល់ពួកគាត់ក្នុងការផ្តល់យុត្តិធម៌ដល់គូភាគី ។
8. ត្រួតពិនិត្យវាយតម្លៃលើការអនុវត្តតួនាទីរបស់មន្ត្រីពាក់ព័ន្ធក្នុងការដោះស្រាយវិវាទដីធ្លី ដាក់ពិន័យ និងអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

ឧបសម្ពន្ធទី(១)៖

| ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២១ - (តាមខេត្តនិមួយៗ) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខេត្ត | ចំនួនករណីវិវាទ | ទំហំដីវិវាទ (ហិចតា) | ចំនួនគ្រួសាររងគ្រោះ | ចំនួនមនុស្សរងគ្រោះ | ជាប់បណ្ដឹងអាជ្ញា (ដាក់ក្រោមការត្រួតពិនិត្យ) | | (ចាប់ខ្លួន) ឃុំខ្លួនបណ្ដោះអាសន្ន | | ករណី (សរុប) |
| | | | | | ចំនួនករណី | ចំនួនមនុស្ស | ចំនួនករណី | ចំនួនមនុស្ស | |
| កោះកុង | 23 | 1,868.33 | 1,108 | 4,587 | 1 | 1 | | | 1 |
| ក្រចេះ | 05 | 67.95 | 83 | 98 | 4 | 18 | | | 4 |
| កំពង់ចាម | 01 | 1964 | 642 | 2568 | | | | | |
| កំពង់ឆ្នាំង | 04 | 70.77 | 503 | 1523 | 2 | 5 | | | 2 |
| កំពង់ធំ | 02 | 594 | 262 | 916 | | | 1 | 2 | 1 |
| កំពង់ស្ពឺ | 23 | 13857.74 | 3270 | 13614 | 5 | 15 | | | 5 |
| កំពត | 01 | 640 | 154 | 227 | | | | | |
| ព្រះសីហនុ | 04 | 542 | 305 | 783 | 1 | 1 | | | 1 |
| ត្បូងឃ្មុំ | 01 | 785 | 128 | 640 | 1 | 44 | 1 | 1 | 1 |
| បន្ទាយមានជ័យ | 06 | 3678.85 | 2888 | 5876 | 3 | 7 | | | 3 |
| បាត់ដំបង | 01 | 1200 | 222 | 856 | 1 | 4 | | | 1 |
| ពោធិសាត់ | 01 | 1000 | 281 | 1405 | 1 | 3 | | | 1 |
| ព្រៃវែង | | | | | | | | | |
| ព្រះវិហារ | 09 | 2410 | 680 | 2639 | 1 | 1 | | | 1 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| មណ្ឌលគិរី | | | | | | | | | |
| រតនៈគិរី | 07 | 2510.55 | 329 | 376 | 2 | 2 | | | 2 |
| សៀមរាប | 26 | 5831.79 | 1390 | 6277 | 4 | 4 | | | 4 |
| ស្ទឹងត្រែង | 43 | 11648.50 | 3556 | 13369 | 1 | 1 | 1 | 1 | 2 |
| ស្វាយរៀង | 01 | 99.66 | 117 | 351 | 1 | 2 | | | 1 |
| ឧត្តមានជ័យ | 07 | 757.73 | 165 | 614 | 6 | 28 | 1 | 1 | 7 |
| កណ្តាល | 04 | 3075 | 950 | 4750 | 1 | 21 | 3 | 12 | 3 |
| **សរុប** | **169** | **52,601.87** | **17,033** | **61,469** | **35** | **157** | **6** | **17** | **40** |

## ឧបសម្ពន្ធទី(២)៖ ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២១ - (តាមអាណិត្ត)

| ល.រ | ប្រភេទករណីវិវាទ | ចំនួនវិវាទ |
|---|---|---|
| 1 | កាប់ទន្រ្ទានព្រៃសហគមន៍ | 01 |
| 2 | ការចូលកាន់កាប់ដោយពលរដ្ឋក្រីក្រលើដីទំនេរ | 02 |
| 3 | ការចូលកាន់កាប់ដោយពលរដ្ឋក្រីក្រលើដីរដ្ឋ | 05 |
| 4 | ការបណ្តេញចេញ | 03 |
| 5 | ការរំលោភចូលទន្រ្ទានយកដីអនាធិបតេយ្យ | 06 |
| 6 | ជម្លោះដីក្នុងគម្រោងដែននេសាទ | 01 |
| 7 | ដែននេសាទ | 03 |
| 8 | រំលោភដណ្តើមដីធ្លីដោយក្រុមហ៊ុនឯកជន | 10 |
| 9 | រំលោភដោយបុគ្គលមានអំណាច | 66 |
| 10 | រំលោភដោយស្ថាប័នរដ្ឋ | 13 |
| 11 | រំលោភដោយអ្នកមានទ្រព្យ | 27 |
| 12 | វារីអគ្គិសនី | 01 |
| 13 | សម្បទានដីសង្គមកិច្ច | 05 |
| 14 | សម្បទានដីសេដ្ឋកិច្ច | 14 |
| 15 | ការកាប់រាន ឈូសឆាយ ហ៊ុំព័ទ្ធដីព្រៃខុសច្បាប់ដោយអ្នកមានទ្រព្យ-មានអំណាច | 11 |
| 16 | សម្បទានរ៉ែ | 01 |
| **សរុបករណីវិវាទ** | | **169** |

ឧបសម្ពន្ធទី(៣)៖

| ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២០ - (តាមខេត្តនិមួយៗ) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខេត្ត (១៧) | ចំនួនករណីវិវាទ | ទំហំដីវិវាទ (ហិចតា) | ចំនួនគ្រួសាររងគ្រោះ | ចំនួនមនុស្សរងគ្រោះ | ជាប់បណ្ដឹងអាជ្ញា (ដាក់ក្រោមការត្រួតពិនិត្យ) | | (ចាប់ខ្លួន) ឃុំខ្លួនបណ្ដោះអាសន្ន | | ករណី (សរុប) |
| | | | | | ចំនួនករណី | ចំនួនមនុស្ស | ចំនួនករណី | ចំនួនមនុស្ស | |
| កោះកុង | 13 | 3,389.66 | 750 | 3,912 | 3 | 6 | 1 | 1 | 4 |
| ក្រចេះ | 8 | 3,820.33 | 757 | 2,016 | 4 | 14 | | | 4 |
| កំពង់ចាម | 1 | 16 | 53 | 159 | | | | | 0 |
| កំពង់ឆ្នាំង | 6 | 998.53 | 812 | 2,672 | 2 | 7 | | | 2 |
| កំពង់ធំ | 5 | 735.27 | 288 | 1,071 | 2 | 2 | | | 2 |
| កំពង់ស្ពឺ | 13 | 9,962.62 | 1,810 | 6,308 | 5 | 9 | | | 5 |
| កំពត | 4 | 78.04 | 118 | 438 | 1 | 1 | | | 1 |
| ព្រះសីហនុ | 9 | 625.53 | 698 | 1,480 | 1 | 5 | 2 | 11 | 3 |
| ត្បូងឃ្មុំ | 3 | 6,747.24 | 5,326 | 10,968 | 1 | 33 | 1 | 2 | 1 |
| បន្ទាយមានជ័យ | 4 | 111.86 | 454 | 1,094 | 1 | 5 | | | 1 |
| បាត់ដំបង | 3 | 2986 | 510 | 591 | 2 | 10 | | | 2 |
| ព្រៃវែង | 2 | 3.2 | 691 | 3,414 | 1 | 2 | | | 1 |
| ព្រះវិហារ | 15 | 4,077.63 | 2,021 | 5,984 | 7 | 39 | | | 7 |
| មណ្ឌលគីរី | 12 | 479.15 | 1,477 | 8,780 | 2 | 2 | | | 2 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| រតនៈគីរី | 26 | 8,649.67 | 2,908 | 8,537 | 3 | 6 | | | 3 |
| សៀមរាប | 19 | 1,625.68 | 1,266 | 6,032 | 3 | 15 | | | 3 |
| ស្ទឹងត្រែង | 35 | 12,763.48 | 3,446 | 13,888 | 4 | 6 | | | 4 |
| ឧត្តមានជ័យ | 4 | 16.96 | 6 | 17 | 1 | 3 | | | 1 |
| **សរុប** | **182** | **57,086.85** | **23,391** | **77,361** | **43** | **165** | **4** | **14** | **46** |

## ឧបសម្ពន្ធទី(៤)៖ ទិន្នន័យវិវាទដីធ្លីឆ្នាំ២០២០ - (តាមអាណិត្ត)

| No | ប្រភេទករណីវិវាទ | ចំនួនវិវាទ |
|---|---|---|
| 1 | កាប់ទន្ទ្រានព្រៃសហគមន៍ | 4 |
| 2 | ការចូលកាន់កាប់ដោយពលរដ្ឋក្រីក្រលើដីទំនេរ | 2 |
| 3 | ការចូលកាន់កាប់ដោយពលរដ្ឋក្រីក្រលើដីរដ្ឋ | 8 |
| 4 | ការបណ្តេញចេញ | 4 |
| 5 | ការរំលោភចូលទន្ទ្រានយកដីអនាធិប្បតេយ្យ | 12 |
| 6 | ដីរ៉ែ | 1 |
| 7 | រំលោភដណ្តើមដីធ្លីដោយក្រុមហ៊ុនឯកជន | 11 |
| 8 | រំលោភដោយបុគ្គលមានអំណាច | 93 |
| 9 | រំលោភដោយស្ថាប័នរដ្ឋ | 11 |
| 10 | រំលោភដោយអ្នកមានទ្រព្យ | 20 |
| 11 | វារីអគ្គិសនី | 1 |
| 12 | សម្បទានដីសង្គមកិច្ច | 2 |
| 13 | សម្បទានដីសេដ្ឋកិច្ច | 11 |
| 14 | សម្បទានរ៉ែ | 2 |
| **សរុបករណីវិវាទ** | | **182** |